៤

# សេចក្តីល្បួង

ការរៀបចំខ្លួន និង ការឆ្លើយតបទៅនឹងការល្បួងនានា

## សៀវភៅសំរាប់សិស្ស

**សិក្សាជាក្រុម**

សំរាប់**គ្រិស្តបរិស័ទថ្មី**

## មាតិកា

### ជំពូក ទី១

**ការល្បួងនៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទថ្មី ........................................៣**

ក. តើការល្បួងគឺជាអ្វី? ........................................៣

ខ. តើការល្បួងស៊ុគ្គាទៅនឹងជីវិតនៃគ្រីស្ទបរិស័ទដោយរបៀបណា? ........................................៤

គ. តើអារក្សសាតាំងអោយអ្នកធ្វើវាឬ? ........................................៦

ឃ. តើតំរូវការនៅក្នុងជីវិតរបស់អ្នកស៊ុគ្គាជាមួយនឹងការល្បួងដោយរបៀបណា? ........................................៧

ង. តើចំណង់របស់អ្នកស៊ុគ្គាជាមួយនឹងការល្បួងដោយរបៀបណា? ........................................៩

### ជំពូក ទី២

**ដំណើរការនៃការយកជ័យជំនះលើការល្បួង ........................................១២**

ក. តើអ្នកឈរនៅឯណា? ........................................ ១២

ខ. តើនោះគឺជាការល្បួងឬ? ........................................១៣

គ. តើជំហានអ្វីដើម្បីយកជ័យជំនះនៅលើការល្បួង ........................................១៤

### ជំពូក ទី៣

**របៀបរៀបចំខ្លួនសំរាប់ការល្បួង ........................................២០**

ក. ចូលទៅជិតព្រះជាម្ចាស់ ........................................២០

ខ. បំពេញតំរូវការរបស់អ្នកនៅក្នុងផ្លូវរបស់ព្រះជាម្ចាស់ ........................................ ២២

គ. សូមអោយព្រះជាម្ចាស់កំណត់ចំណង់ដែលសមរម្យ ........................................ ២៦

ឃ. ការល្បួងខ្លះអាចការពារបាន ........................................៣១

### ជំពូក ទី៤

**យល់ដឹងការបរាជ័យ និង ដោះស្រាយទាតាមផ្លូវរបស់ព្រះជាម្ចាស់ ........................................៣៤**

ក. តើអ្វីកើតឡើងនៅពេលអ្នកធ្វើតាមការល្បួង? ........................................៣៤

ខ. តើហេតុអ្វីបានជាអ្នកធ្វើតាមការល្បួង? ........................................៤០

គ. តើអ្នកគួរតែធ្វើអ្វីបន្ទាប់ពីអ្នកបានធ្វើតាមការល្បួង? ........................................៤៥

# ជំពូក ទី១

# ការល្បួងនៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទថ្មី

សំរាប់គ្រីស្ទបរិស័ទថ្មីខ្លះ ពាក្យថា " ការល្បួង " មានន័យថា ជាបញ្ហា ។ " អារក្សសាតាំងវាចេញមកដើម្បីធ្វើអោយខ្ញុំជាប់អន្ទាក់ទៀតហើយ ។ ពួកវាដកដង្ហើមធំ ។

ប៉ុន្តែតើគ្រីស្ទបរិស័ទថ្មីត្រូវតែមានការភ័យខ្លាចចំពោះការល្បួងដែរឬទេ? តើការល្បួងគឺជាអ្វីពិតប្រាកដ? តើមនុស្សម្នាក់អាចយកជ័យជំនះក្នុងការប្រឆាំងការល្បួងដោយរបៀបណា?តើគេអាចការពារការល្បួងបានដែរឬទេ?តើអ្នកអាចធ្វើអ្វីដើម្បីរៀបចំខ្លួនសំរាប់ការល្បួង?តើអ្នកគួរតែធ្វើអ្វីបន្ទាប់ពីអ្នកបានយល់ព្រមធ្វើតាមការល្បួង? ទាំងនេះគឺជាសំនួរខ្លះៗដែលមាននៅក្នុងវគ្គសិក្សានេះ ។

សូមអោយយើងចាប់ផ្តើមដោយកំណត់និយមន័យ ការល្បួង ។

## ក. តើការល្បួងគឺជាអ្វី?

មនុស្សខ្លះប្រើពាក្យថា " ការល្បួង " នៅក្នុងផ្លូវទូទៅមួយ ។ ពួកគេហៅថាការសាកល្បង, ការលំបាក, ឬក៏ បញ្ហា ថាជា " ការល្បួង " ។ នៅពេលដែលយើងប្រើពាក្យថា " ការល្បួង " នៅក្នុងវគ្គសិក្សានេះ យើងនឹងយោងទៅលើស្ថានភាពទាំងឡាយណាដែលសាតាំងកំពុងតែព្យាយាមធ្វើអោយមនុស្សម្នាក់ធ្វើអំពើបាប ។

នេះគឺជានិយមន័យជាក់លាក់មួយនៃការល្បួងដែលយើងនឹងប្រើ : នៅពេលសាតាំងព្យាយាមអោយអ្នកធ្វើខុសវិន័យរបស់ព្រះជាម្ចាស់ក្នុងការបំពេញសេចក្តីត្រូវការ ឬក៏ ចំណង់នៅក្នុងជីវិតរបស់អ្នក ។

សាតាំងវាចូលចិត្តនាំអោយមនុស្សដើរផ្លូវខុស ។ វាទាក់ទងទៅនឹងការិតសើៗនៃតំរូវការ និង ធ្វើអោយអ្នកជឿថាវាគឺជាបញ្ហាពិតប្រាកដ ។ វាបោកបញ្ឆោតអោយអ្នកគិតពីបញ្ហារបស់អ្នកដោយអោយអ្នកពេញចិត្តជាមួយនឹងការបំពេញតំរូវការនៅក្នុងផ្លូវមួយស្រួល និង លឿនបំផុត ។ អ្វីដែលយើងទទួលបាននៅពេលដែលយើងធ្វើតាមការផ្តល់យោបល់របស់វា និង ធ្វើអ្វីដែលវាប្រាប់អ្នក

អោយធ្វើគឺ អ្នកនឹងធ្វើខុសវិន័យរបស់ព្រះជាម្ចាស់យ៉ាងតិចមួយ ។

វាមិនមែនជាអំពើបាប ឬក៏ កំហុសអំពីតំរូវការនៅក្នុងជីវិតរបស់អ្នក នោះទេ ។ ព្រះជាម្ចាស់បានបង្កើតអ្នកអោយមានពិសោធន៍ចំពោះកិច្ចការនេះ ។ ប៉ុន្តែល្បិចរបស់សាតាំងគឺព្យាយាមធ្វើយ៉ាងម៉េចអោយអ្នកបំពេញតំរូវការរបស់អ្នកតាមវិធីមួយដែលមិនគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។

ប្រសិនបើអ្នកឃ្លាន សាតាំងនឹងព្យាយាមអោយអ្នកមើលឃើញតំរូវការរបស់អ្នកពីផ្លូវមួយដែលមិនសមរម្យ ។ អ្នកឃ្លាន នេះគឺជាផ្លូវដ៏ស្រួលបំផុតដើម្បីបំពេញតំរូវការរបស់អ្នក ។ លួចនំប៉័ងដាក់សាច់នោះទៅ ទាន់គេមិននៅ ។ គ្មាននរណាម្នាក់មើលឃើញនោះទេ ហើយក៏គ្មាននរណាម្នាក់ឈឺចាប់ផងដែរ ។ គាត់នឹងយកទាំងអស់មិនអោយសល់នំប៉័ងតូចមួយនោះទេ ។ " សាតាំងបោកបញ្ឆោតអ្នកអោយគិតទៅតាមដំណោះស្រាយរបស់វាចំពោះបញ្ហារបស់អ្នក គឺមើលទៅវាសមហេតុសមផលណាស់ ។ ប៉ុន្តែសាតាំងតែងតែលើកទឹកចិត្តចំពោះដំណោះស្រាយតាមផ្លូវអាត្មានិយមដែលតែងតែនាំទៅការប្រព្រឹត្តអំពើបាប ។

តើព្រះជាម្ចាស់ល្បួងមនុស្សអោយធ្វើអំពើបាបឬ? យ៉ាកុប ១:១៣-១៤ ផ្តល់នូវចំលើយយ៉ាងច្បាស់ចំពោះសំនួរនេះ ។

**យ៉ាកុប ១:១៣-១៤**

**ពេលនរណាម្នាក់ជួបនឹងការល្បួងមិនត្រូវពោលថា " ព្រះជាម្ចាស់ល្បួងខ្ញុំ " ឡើយ ដ្បិតគ្មានអ្វីអាចល្បួងព្រះជាម្ចាស់អោយធ្វើអំពើអាក្រក់បានឡើយ ហើយព្រះអង្គផ្ទាល់ក៏មិនល្បួងនរណាម្នាក់ដែរ ។ ម្នាក់ៗជួបនឹងការល្បួង មកតែពីចិត្តលោភលន់របស់ខ្លួនឯងផ្ទាល់ទាក់ទាញ និង លួងលោមបញ្ឆោតប៉ុណ្ណោះ ។**

ការល្បួងចាប់ផ្តើម ជាគំនិត !

វាច្បាស់ណាស់ថា ព្រះជាម្ចាស់មិនល្បួងគ្រីស្តបរិស័ទអោយធ្វើអំពើបាបនោះទេ ។ ប៉ុន្តែនៅពេលដូចគ្នានោះដែរ តំរូវការរបស់អ្នកគឺមានពិតប្រាកដ ។

**ខ. តើការល្បួងស្ទុះស្ទាទៅនឹងជីវិតនៃគ្រីស្តបរិស័ទដោយរបៀបណា?**

ជាធម្មតា ទីលានប្រយុទ្ធសំរាប់ការល្បួងគឺចិត្តគំនិតរបស់យើង ។ ការល្បួងចាប់ផ្តើមជាគំនិត ។ សុខមើលទៅអាវរងារដ៏ស្រស់ស្អាត ហើយគិតថា "ខ្ញុំរងារណាស់ ខ្ញុំពិតជាត្រូវការអាវរងារនេះ ។ ខ្ញុំគិតថា ខ្ញុំអាចលួចវាដោយគេចាប់មិនបាន ។ " ការវាយតំលៃនៃគំនិតដំបូងរបស់លោក សុខនឹងកំណត់សកម្មភាពរបស់គាត់ ។ ប្រសិនបើគាត់ជ្រើសរើសធ្វើតាមការល្បួងនោះ គាត់នឹងប្រហែលជាព្យាយាម

លួចវា ។ គាត់ក៏អាចជ្រើសរើសប្រឆាំងទៅនឹងការល្បួងផងដែរ ។

ឥរិយាបថរបស់អ្នកមានឥទ្ធិពលយ៉ាងខ្លាំងក្លាដល់ការឆ្លើយតបរបស់អ្នកចំពោះការល្បួង ។ ប្រសិនបើអ្នកបានបង្កើតគំរូនៃការគិតតាមព្រះគម្ពីរនោះវានឹងមានការងាយស្រួលសំរាប់អ្នកក្នុងការប្រឆាំងជាមួយនឹងការល្បួង ។ យើងនឹងមើលអោយកាន់តែជិតនូវបញ្ហានេះពេលក្រោយ នៅក្នុងមុខវិជ្ជានេះ ។

វាមានបញ្ហាច្រើនណាស់សំរាប់គ្រីស្ទបរិស័ទច្រើនជាងការតយុទ្ធជាមួយសាតាំងគ្រប់ពេលវេលានោះ ។ កុំទៅស្វែងរកការល្បួង ។ សូមផ្តោតការយកចិត្តទុកដាក់របស់អ្នកទៅលើការរស់នៅជាជីវិតគ្រីស្ទបរិស័ទដោយធ្វើតាមគំរូរបស់ព្រះគ្រីស្ទ ។ នៅពេលដែលការល្បួងមករកអ្នក សូមគិតថាវាគឺជាឱកាសដើម្បីចូលអោយកាន់តែជិតព្រះជាម្ចាស់ ។ ទ្រង់គឺជាព្រះតែមួយគត់ដែលផ្តល់អោយអ្នកនូវអំណាច និង ប្រាជ្ញាដើម្បីយកឈ្នះគ្រប់ការល្បួងដែលមករកអ្នក ។

វាធម្មតាទេ សំរាប់គ្រីស្ទបរិស័ទដែលជួបការល្បួងធ្វើអំពើបាបនោះ ។ មនុស្សម្នាក់នឹងជួបប្រទះការល្បួង ទោះជាវិញ្ញាណគាត់ដល់កំរិតណាក៏ដោយ ។ អ្នកអាចរំពឹងទុកក្នុងការប្រឈមមុខជាមួយនឹងការល្បួងសំរាប់ជីវិតដែលនៅសល់របស់អ្នក ។ ប៉ុន្តែ អ្នកអាចមានជ័យជំនះឈ្នះគ្រប់អស់ទាំងការល្បួង ។

ព្រះគម្ពីរប្រាប់យ៉ាងច្បាស់ថា វាមិនមែនជាអំពើបាបទេ ក្នុងការជួបការល្បួងនោះ ។ ព្រះយេស៊ូជួបការល្បួងអោយធ្វើអំពើបាបជាច្រើនដង ។ សាតាំងបានបង្ហាញសេចក្តីត្រូវការដែលព្រះយេស៊ូមាននៅក្នុងជីវិតរបស់ទ្រង់ដោយប្រើការលើកឡើងដូចគ្នាចំពោះសកម្មភាពអាត្មានិយមដែលវាប្រើជាមួយអ្នក ។ ប៉ុន្តែព្រះគ្រីស្ទប្រឆាំងនឹងការល្បួងយ៉ាងម៉ឺងម៉ាត់ ។

**ហេប្រឺ ៤:១៥ ដ្បិតយើងមានមហាបូជាចារ្យដែលអាចរួមសុខទុក្ខជាមួយយើងជាមនុស្សទន់ខ្សោយគឺព្រះអង្គក៏ត្រូវរងការល្បួងលគ្រប់ជំពូកដូចយើងដែរ តែទ្រង់មិនបានប្រព្រឹត្តអំពើបាបសោះឡើយ ។**

ការជួបការល្បួង និង ការប្រព្រឹត្តការល្បួងគឺវាខុសគ្នាស្រលះ ។ អ្នកមិនចាំបាច់មានអារម្មណ៍ថាមានកំហុសនោះទេ ប្រសិនបើអ្នកកំពុងតែជួបប្រទះនឹងការល្បួងច្រើននោះ កុំអោយតែអ្នកធ្វើតាមដំណោះស្រាយរបស់សាតាំង ។ រាល់ការល្បួងទាំងអស់អាចជាឱកាសមួយសំរាប់អោយអ្នកក្លាយទៅជាគ្រីស្ទបរិស័ទរឹងមាំ ។

## គ. តើអារក្សសាតាំងអោយអ្នកធ្វើវាឬ?

តាមពិតទៅអ្នកមិនអាចនិយាយថា " អារក្សសាតាំងអោយខ្ញុំធ្វើវានោះទេ ។ " ទាំងព្រះជាម្ចាស់ និង អារក្សសាតាំងនឹងផ្តល់ឱកាសអោយអ្នកបំពេញតំរូវការ និង បំណងប្រាថ្នារបស់អ្នក ប៉ុន្តែមិនបង្ខំអោយអ្នកធ្វើតាមរបៀបនោះទេ ការសំរេចចិត្តគឺនៅលើអ្នកខ្លួនឯងផ្ទាល់ ។

យើងអាចនិយាយថា ឱកាសទាំងនេះបំពេញសេចក្តីត្រូវការរបស់អ្នកដូចជាទ្វារអញ្ចឹង ។ សាតាំង និង ព្រះជាម្ចាស់នឹងដាក់ទ្វារនៅពីមុខអ្នក ។ ទាំងព្រះជាម្ចាស់ ទាំងសាតាំងលើកទឹកចិត្តអ្នកអោយដោះស្រាយបញ្ហាជាមួយនឹងវិធីសាស្ត្ររបស់អ្នកទាំងពីរ ។ ទ្វារដែលសាតាំងដាក់នៅមុខអ្នកគឺជាការល្បួង ។ ទ្វារដែលព្រះជាម្ចាស់ ដាក់នៅទីនោះគឺមិនអាត្មានិយមទេ តែជាដំណោះស្រាយដែលមានរង្វាន់វិញ ។ ជួនកាលព្រះជាម្ចាស់ប្រហែលជាដាក់ទ្វារពីរ ឬក៏ បីនៅខាងមុខនាក់ដើម្បីបំពេញតំរូវការដូចគ្នា ។ សាតាំងប្រហែលជាអាចធ្វើដូចនេះដែរ ។

សាតាំងនឹងប្រហែលជាព្យាយាមអោយទ្វាររបស់វាមើលទៅទាក់ទាញជាងទ្វាររបស់ព្រះជាម្ចាស់ ។ ប៉ុន្តែ វាមិនប្រាប់អ្នកការពិតនោះទេ ។

ឧទាហរណ៍ សុខា ចង់មានមិត្តភ័ក្តិ ។ សិស្សខ្លះនៅក្នុងថ្នាក់របស់គាត់អញ្ជើញគាត់មកចូលរួមជប់លៀងនៅយប់នេះ ។ នៅពេលដែលគាត់មកដល់កន្លែងជប់លៀង គាត់ឃើញថាមនុស្សគ្រប់គ្នាជក់កញ្ឆា ។ សាតាំងបើកទ្វាមួយយ៉ាងទាក់ទាញខាងមុខសុខា ។ " សុខា មើលមិត្តភ័ក្តិ នេះអ្នកអាចសាកបន្តិចទៅវាមិនធ្វើអោយអ្នកឈឺចាប់នោះទេ ។ អ្នកនឹងមានអារម្មណ៍សប្បាយជាមួយនឹងមិត្តភ័ក្តិថ្មីរបស់អ្នក ។ "

នៅចំនុចនេះ ទ្វាររបស់ព្រះជាម្ចាស់ប្រហែលជាមិនទាក់ទាញចំពោះសុខានោះទេ ។ ប្រសិនបើគាត់ដើរតាមផ្លូវរបស់ព្រះជាម្ចាស់ គាត់ត្រូវតែចាកចេញពីកន្លែងជប់លៀងនោះ ។ ប្រសិនបើគាត់ធ្វើដូច្នេះ មនុស្សជាច្រើននៅកន្លែងជប់លៀងនឹងមិនចង់ក្លាយជាមិត្តភ័ក្តិរបស់គាត់នោះទេ ។ ប្រសិនបើគាត់ដើរតាមផ្លូវរបស់ព្រះជាម្ចាស់ គាត់នឹងរកឃើញមិត្តភ័ក្តិថ្មីនៅកន្លែងផ្សេងទៀត ។ ប៉ុន្តែ តើកន្លែងណាដែលគាត់រកមិត្តភ័ក្តិថ្មីបាន? និង ជានរណា?

ប្រសិនបើអ្នកដើរតាមទ្វាររបស់សាតាំង អ្នកនឹងធ្វើខុសវិន័យរបស់ព្រះជាម្ចាស់យ៉ាងតិចមួយ ។ ប៉ុន្តែសាតាំងវាមិនប្រាប់អ្នកអំពីបញ្ហានោះទេ ។ វា

មិននិយាយថា " ស៊ីនឌី នេះគឺជាសាតាំងកំពុងនិយាយ យើងកំពុងតែល្បួងអ្នកអោយធ្វើខុសនឹងព្រះជាម្ចាស់ ។" ទេ សាតាំងមិនធ្វើដូច្នេះនោះទេ សាតាំងវានឹងប្រាប់អ្នកថា ផ្លូវរបស់វាលឿននិង ស្រួលបំផុតក្នុងការបំពេញសេចក្តីត្រូវការពិតប្រាកដនៅក្នុងជីវិតរបស់អ្នក ។

ជួនកាលទ្វាររបស់ព្រះជាម្ចាស់មើលទៅមិនទាក់ទាញនោះទេ ។ ប៉ុន្តែនៅក្នុងពេលដ៏យូរ វិធីរបស់ព្រះជាម្ចាស់តែងតែបង្ហាញនូវវិធីដ៏ល្អបំផុតដើម្បីបំពេញតំរូវការនោះ ឬក៏ បំណងនៅក្នុងជីវិតរបស់អ្នក ។ វិធីរបស់សាតាំងមើលទៅទាក់ទាញ ពីព្រោះវាមិនប្រាប់អ្នកនូវផលវិបាកនៃការធ្វើកិច្ចការនោះតាមវិធីរបស់វានោះទេ ។ វាគ្រាន់តែប្រាប់អ្នកពីរបៀបដើរតាមទ្វាររបស់វានឹងជួយបំពេញតំរូវការរបស់អ្នកឥឡូវនេះ ។ សាតាំងមិនបានប្រាប់ អេវ៉ានៅក្នុងសួនអេដែនថា ព្រះជាម្ចាស់នឹងអោយគាត់ចេញពីសួននិង ត្រូវជួបប្រទះនូវផលវិបាកដ៏គួរអោយខ្លាចនៃអំពើបាបនោះទេ ប្រសិនបើគាត់បានហូបផ្លែពីដើមឈើមួយនោះ ។ នៅពេលដែលអេវ៉ាដើរតាមទ្វាររបស់សាតាំងមានន័យថា គាត់បានឃ្លាតឆ្ងាយពីការការពាររបស់ព្រះជាម្ចាស់ទៅហើយ ។

ព្រះជាម្ចាស់ចង់អោយយើងពិសោធន៍ជីវិតដែលពេញបរិបូរណ៏ដែលតំរូវការនីមួយៗត្រូវបានបំពេញ ។ សូមអោយយើងមើលកាន់តែជិតនូវតំរូវការដែលយើងមាននៅក្នុងជីវិតរបស់យើងនិង ពីរបៀបដែលពួកវាទាក់ទងទៅនឹងការល្បួងដែលយើងប្រឈមមុខ

**ឃ. តើតំរូវការនៅក្នុងជីវិតរបស់អ្នកស៊ីគ្នាជាមួយនឹងការល្បួងដោយរបៀបណា?**

គំរោង ទី ២ ដែលស៊ីគ្នាជាមួយនឹងមុខវិជ្ជានេះសួរអោយអ្នកបង្ហាញនូវការល្បួងច្រើនដែលអ្នកបានជួបប្រទះថ្មីៗនេះ ។ អ្នកអាចចងចាំទុកនូវស្ថានភាពទាំងនោះ នៅពេលអ្នកមើលព័ត៌មានខាងក្រោមអំពីតំរូវការរបស់អ្នក ។

ការមើលតំរូវការដែលយើងមាននៅក្នុងជីវិតរបស់យើង វាមានប្រយោជន៏ បើយើងបានប្រើផ្នែកទូទៅខ្លះៗសំរាប់សំគាល់តំរូវការមួយណាដែលដូចគ្នា ។ នេះគឺជាវិធីមួយដើម្បីដាក់តំរូវការរបស់អ្នកជាក្រុម ។ ឧទាហរណ៏ត្រូវបានផ្តល់ជូនជាក្រុមនៅខាងក្រោម ។

## សេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្ស

១. តំរូវការខាងសរីរាង្គកាយ - ម្ហូប, សំលៀកបំពាក់, ភាពកក់ក្តៅ

២. តំរូវការខាងសុវត្ថិភាព - ជាកម្មសិទ្ធ, ត្រូវបានការពារ-ចែកចាយនូវអត្តសញ្ញាណជាមួយក្រុម-យល់ដឹងពីច្បាប់នៃជីវិត

៣. តំរូវការខាងសង្គម-មានមិត្តភ័ក្តិជិតស្និទ្ធ

- មានកន្លែងមួយដែលមានផាសុខភាព
- មានមិត្តភាពជាមួយអ្នកដទៃដែលគិតដូចគ្នា ទាំងមនុស្សប្រុស និង មនុស្សស្រី
- ស្រលាញ់គេ និង គេស្រលាញ់ខ្លួន

៤. តំរូវការខាងការគោរពខ្លួនឯង- អ្នកដទៃទទួលយកខ្លួន - អ្នកដទៃគោរពខ្លួន - គេចាត់ទុកថាខ្លួនសំខាន់

៥. តំរូវការខាងការសំរេចគោលដៅ-ដើម្បីប្រើនូវសមត្ថភាព និង ជំនាញរបស់អ្នក

- ធ្វើកិច្ចការមានអត្ថន័យដែលផ្តល់អោយអ្នកនូវស្មារតីសំរេចការងារ
- ដឹងថាអ្នកកំពុងតែរីកធំធាត់ជាមនុស្សពេញវ័យ
- មើលឃើញភាពរីកចំរើននៅក្នុងការងាររបស់អ្នក

៦. តំរូវការខាងព្រលឹងវិញ្ញាណ-ស្គាល់ព្រះជាម្ចាស់ផ្ទាល់ខ្លួន, ពេញដោយព្រះវត្តមានរបស់ទ្រង់

- អំពើបាបរបស់អ្នកត្រូវបានអត់ទោស ព្រះអង្គដកអស់នូវភាពមានកំហុសពីជីវិតរបស់អ្នក
- ជាគ្រីស្តបរិស័ទប្រកបទៅដោយជ័យជំនះ, ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់

ព្រះជាម្ចាស់បង្កើតយើងជាមួយនឹងតំរូវការទាំងនេះ ។ ព្រះអង្គផ្តល់ផ្លូវឱ្យយើងដើម្បីបំពេញតំរូវការនីមួយៗទាំងនេះ ។

ដូច្នេះ តើតំរូវការមួយណាដែលសំខាន់បំផុត?

សាតាំងនឹងល្បួងអ្នកនៅក្នុងកន្លែងដែលអ្នកមានតំរូវការដែលមិនទាន់បានបំពេញនៅពេលថ្មីៗនេះ ។ ឧទាហរណ៍ សាតាំងនឹងមិនល្បួងអ្នកអោយលួចម្ហូប បន្ទាប់ពីអ្នកបានញ៉ាំយ៉ាងឆ្អែត ១៥ នាទីនៅពេលល្ងាចថ្ងៃបុណ្យអរព្រះគុណនោះទេ ។ ប៉ុន្តែយើងឃើញថា សាតាំងបានល្បួងព្រះយេស៊ូអោយទ្រង់ធ្វើដុំថ្មក្លាយទៅជានំប៉័ង បន្ទាប់ពីព្រះយេស៊ូបានតមអាហារអស់រយៈពេល ៤០ ថ្ងៃ ។ ព្រះគម្ពីរបានចែងថា ពេលដែលសាតាំងល្បួងព្រះយេស៊ូអោយទ្រង់ធ្វើដុំថ្មក្លាយជានំបុ័ងគឺនៅពេលនោះព្រះយេស៊ូឃ្លានណាស់ ។ ព្រះយេស៊ូមានតំរូវការខាងម្ហូបពិតប្រាកដណាស់ ។

នៅក្នុងករណីខ្លះ ប្រសិនបើតំរូវការមួយមិនបានបំពេញនោះទេ វានឹងធ្វើអោយមានតំរូវការដទៃទៀត ។ ប្រសិនបើអ្នកមិនចេះហែលទឹក ហើយមានគេរុញអ្នកអោយធ្លាក់ពីលើផែ ដែលមានទឹកជ្រៅ នោះមានន័យថាតំរូវការដែលសំខាន់បំផុតនៅពេលនោះគឺខ្យល់សំរាប់ដកដង្ហើមដែលជាតំរូវការសំខាន់ជាងតំរូវការផ្សេងៗទៀតដែលអ្នកមាន ។ អ្នកនឹងភ្លេចឃ្លាន ឬក៏ ភ្លេចការប្រលងនៅថ្ងៃស្អែក ។

ក្រុម ៥ ដំបូងនៃតំរូវការដែលត្រូវបានបង្ហាញនៅលើទំព័រ ទី ៧ និង ទី ៨ ដែលភាគច្រើនវាប្រព្រឹត្តទៅតាមលំដាប់លំដោយរបស់វា ។ តំរូវការខាងសរីរាង្គកាយត្រូវតែបំពេញ មុននឹងមនុស្សម្នាក់នឹងព្យាយាមបំពេញតំរូវការខាងសុវត្ថិភាព ។ មនុស្សម្នាក់

ត្រូវតែមានសុវត្ថិភាពមុននឹងគាត់អាចពិសោធនៃការបំពេញខាងសង្គម, ការគោរពខ្លួនឯង និង តំរូវការសំរេចគោលដៅ ។ វាមិនចាំបាច់ដើម្បីធ្វើអោយស្កប់គ្រប់ទាំងអស់នៃតំរូវការដទៃទៀតរបស់អ្នក មុននឹងអ្នកអាចបំពេញតំរូវការខាងព្រលឹងវិញ្ញាណនោះទេ កិច្ចការទាំងនេះអាចមានឥទ្ធិពលយ៉ាងធំទៅលើរបៀបយ៉ាងងាយស្រួលដើម្បីបំពេញកិច្ចការខាងព្រលឹងវិញ្ញាណ ។ ប្រសិនបើមនុស្សម្នាក់ឃ្លានខ្លាំង គាត់ប្រហែលជាមិនចាប់អារម្មណ៍នៅក្នុងការភាក្សាបញ្ហាញខាងព្រលឹងវិញ្ញាណរបស់គាត់នោះទេ ។

ប្រសិនបើអ្នកនឹងក្លាយទៅជាគ្រីស្តបរិស័ទប្រកបដោយជោគជ័យនោះ វាសំខាន់ណាស់ក្នុងការរកឱ្យឃើញនូវវិធីរបស់ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការនីមួយៗរបស់អ្នក ។ អ្នកត្រូវតែរៀនសំគាល់អោយបានច្បាស់លាស់នូវតំរូវការពេលដែលវាកើតឡើងភ្លាមៗ ។ ប៉ុន្តែជាច្រើនដង សាតាំងនឹងធ្វើអោយអ្នកចាប់អារម្មណ៍ចំពោះចំណង់របស់អ្នក និង ព្យាយាមអោយអ្នកជឿថា វាគឺជាតំរូវការពិតប្រាកដ ។ សូមអោយយើងមើលឱ្យកាន់តែជិតនូវចំណង់របស់យើង និង ពីរបៀបដែលវាស៊ីគ្នាជាមួយនឹងការល្បួង ។

**សាតាំងនឹងធ្វើឱ្យអ្នកចាប់អារម្មណ៍ចំពោះចំណង់របស់អ្នក និង ព្យាយាមឱ្យអ្នកជឿថាវាគឺជាតំរូវការពិតប្រាកដ ។**

### ខ. តើចំណង់របស់អ្នកស៊ីគ្នាជាមួយនឹងការល្បួងដោយរបៀបណា?

តើរវាងតំរូវការ និង ចំណង់ខុសគ្នាយ៉ាងដូចម្តេច? តើចំណង់ក្លាយទៅជាតំរូវការឬទេ? តើព្រះជាម្ចាស់បារម្ភពីការបំពេញខាងតំរូវការរបស់អ្នក ឬក៏ ទ្រង់ចង់ធ្វើឱ្យចំណង់របស់អ្នកស្កប់ផងដែរ? តើមនុស្សម្នាក់អាចមានចំណង់បាបឬទេ? តើគ្រីស្តបរិស័ទអាចដឹងដោយរបៀបណាប្រសិនបើអ្វីដែលគាត់ចង់បានគាប់ព្រះទ័យព្រះជាម្ចាស់នោះ?

ការល្បួងលើកដំបូងដែលត្រូវបានកត់នៅក្នុងព្រះគម្ពីរគឺនិយាយអំពីចំណង់មិនមែនតំរូវការពិតប្រាកដនោះទេ (សូមអាន កំណើតពិភពលោក ជំពូក ទី ៣) ។ សាតាំងបានធ្វើអោយ អេវ៉ាជឿថា ប្រសិនបើគាត់ញ៉ាំផ្លែឈើចេញពីផ្លែមួយដើមនោះ គាត់នឹងដូចព្រះជាម្ចាស់ និង យល់ដឹងភាពខុសគ្នារវាងអាក្រក់ និង ល្អ ។ តើអេវ៉ាត្រូវតែដូចព្រះអង្គឬ? ទេ, ប៉ុន្តែអារក្សសាតាំងធ្វើអោយអេវ៉ាស្តាប់ទៅដូចជាល្អ និង ជួយអោយគាត់ក្លាយទៅជាមនុស្សល្អប្រសើរទៀតផង ។ ពេលចំណង់របស់គាត់គ្រប់គ្រងគាត់បានហើយ គាត់បានធ្វើអំពើបាបដោយមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ។

ចំណង់របស់យើងខ្លះវាទាក់ទងគ្នាយ៉ាងជិតស្និទ្ធទៅនឹងតំរូវការរបស់យើង ។ យើងតំរូវអោយមានម្ហូបគ្រប់គ្រាន់រាល់ថ្ងៃ ប៉ុន្តែយើងភាគច្រើនចង់ញ៉ាំច្រើនជាងតំរូវការ-ដំឡូងបង្អែម, ស្ករគ្រាប់ ឬក៏ (ម្ហូបអាហារអ្វីផ្សេង) បន្ថែមទៀត ។ យើងអាចមានទំលាប់ក្នុងការបំពេញចំណង់របស់យើងដែលយើងចាប់ផ្តើមជឿថាយើងពិតជា

ត្រូវការម្ហូបអាហារបន្ថែមនោះ ។

អ្វីដែលបានកើតឡើងនៅក្នុងជីវិតរបស់លោក អាហ៊្វីដូ ត្រូវបានគេលើកឡើងម្តងហើយម្តងទៀតដោយមនុស្សរាប់ពាន់អ្នក ។ គាត់បានចាប់ផ្តើមជក់កញ្ឆាដោយសារតែគាត់ចង់អោយមនុស្សដែលមានអាយុស្រករគាត់ទទួលយកគាត់ ។ សាតាំងបានធ្វើអោយគាត់ចាប់អារម្មណ៏ចំពោះតំរូវការរបស់គាត់សំរាប់មិត្តភ័ក្តិ ។ ថ្ងៃមួយមិត្តភ័ក្តិរបស់គាត់បានណែនាំអោយគាត់ស្គាល់ថ្នាំញៀននោះ ។

អាហ៊្វីដូបានប្រងើយកន្តើយវិធីរបស់ព្រះជាម្ចាស់ក្នុងការជួយគាត់អោយរកមិត្តភ័ក្តិថ្មី ហើយមិនយូរប៉ុន្មាន គាត់បានញៀនអាភៀន ។ រាងកាយរបស់គាត់ចង់ថ្នាំញៀនខ្លាំង ។ អ្វីដែលបានចាប់ផ្តើមគឺគ្រាន់តែជាកិច្ចការមួយដែល គាត់ចង់ធ្វើប៉ុណ្ណោះ តែបានក្លាយទៅជាការគ្រប់គ្រងលើ ជីវិតរបស់គាត់ និងជាកំលាំងបំផ្លាញជីវិតរបស់គាត់ថែមទៀត ។

សាតាំងនឹងធ្វើអ្វីៗទាំងអស់ក្នុងអំណាចរបស់វាដើម្បីធ្វើអោយអ្នកក្លាយទៅជាខ្ញុំកញ្ជះរបស់ចំណង់ខុសឆ្គង ។ ព្រះគម្ពីរបានផ្តល់នូវដំបូន្មានមួយយ៉ាងខ្លាំងទាក់ទងទៅនឹងបញ្ហានេះ ដោយពន្យល់ថាហេតុអ្វីបានជាគ្រីស្តបរិស័ទខ្លះមិនសប្បាយចិត្ត ។

**យ៉ាកុប ៤:១-៣ ការទាស់ទែង ឈ្លោះប្រកែកគ្នាក្នុងចំណោមបងប្អូនកើតមកពីអ្វី? តើមិនមែនមកពីចិត្តស្រើបស្រាលដែលប្រទាញប្រទង់គ្នានៅក្នុងសរីរាង្គកាយរបស់បងប្អូនទេឬ? បងប្អូនមានចិត្តលោភលន់តែមិនបានដូចការប៉ងប្រាថ្នាទេ បងប្អូនក៏សម្លាប់ និង ឈ្នានីសគេហើយនៅតែគ្មានបានផលអ្វីបងប្អូនឈ្លោះប្រកែក និង ទាស់ទែងគ្នាក៏នៅតែមិនបានទទួលអ្វីដែរ ព្រោះបងប្អូនមិនទូលសូមពីព្រះជាម្ចាស់ ។ បងប្អូនទូលសូមដែរតែឥតបានទទួល ព្រោះបងប្អូនទូលសូមដោយបំណងអាក្រក់គឺបងប្អូនចង់បានសំរាប់តែបំពេញចិត្តស្រើបស្រាលរបស់ខ្លួនប៉ុណ្ណោះ ។**

ផ្លូវភេទគឺជាកន្លែងដែលសាតាំងលើកទឹកចិត្តនូវការរំលោភបំពាន និងចំណង់អាក្រក់ជាច្រើនយ៉ាងជោគជ័យ ។ ចំណង់ទំនាក់ទំនងផ្លូវភេទដូចគ្នា, ចំណង់ចង់រួមរ័កជាមួយប្តី ឬក៏ ប្រពន្ធអ្នកដទៃ និង ការរំលោភធ្វើបាបកូនក្មេងគឺជាឧទាហរណ៏ខ្លះៗនៃចំណង់អាក្រក់ដែលទាក់ទងទៅនឹងផ្លូវភេទ ។ គំនិតរវើរវាយខាងផ្លូវភេទត្រូវគ្នានឹងចំនុចទៅទីនេះផងដែរ ។ ចំណង់ផ្សេងៗទៀតដែលសាតាំងវាមានគឺធ្វើឱ្យនរណាម្នាក់ឈឺចាប់ ឬក៏ សម្លាប់នរណាម្នាក់, បំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ , លួច, កុហក, ដាក់បណ្តាសា និង សងសឹក ។ ចំណង់ទាំងនេះគឺអាត្មានិយម, គ្មានសេចក្តីស្រលាញ់ និង ធ្វើអោយតំរូវការពិតប្រាកដខុសពីភាពដើម ។

ព្រះជាម្ចាស់បានបញ្ជាឱ្យយើងចេញអោយផុតពីចំណង់អាក្រក់ទាំងនេះ ។ នៅក្នុងករណីជាច្រើន មានតែព្រះជាម្ចាស់ទេដែលអាចផ្តល់អំណាចអោយអ្នកអាចយកចំណង់អាក្រក់ទាំងនេះចេញពីជីវិតរបស់អ្នកនិង ជំនួសមកវិញនូវអ្វីៗដែលមកពីព្រះអង្គ ។ ក្នុងនាមជាអ្នកដើរ

**មានតែព្រះជាម្ចាស់ទេ ដែលអាចផ្តល់អំណាចឱ្យអ្នកអាចយកចំណង់អាក្រក់ទាំងនេះចេញពីជីវិតរបស់អ្នក និង ជំនួសមកវិញនូវអ្វីៗដែលមកពីព្រះអង្គ ។**

តាមព្រះយេស៊ូគ្រីស្ទ មានន័យថាយើងត្រូវគិតដូចព្រះគ្រីស្ទគិត-មានប្រតិកម្មដូចព្រះអង្គមាន ។

ជួនកាលចំណង់សើៗគ្រប់ដណ្តប់ទាំងស្រុងទៅលើសេចក្តីត្រូវការពិតប្រាកដនៅក្នុងជីវិតរបស់យើង ។ប្រសិនបើអ្នកអាចសំគាល់សេចក្តីត្រូវការដែលជាប់ទាក់ទង កិច្ចការនេះនឹងជួយអ្នកអោយមើលឃើញចំណង់ដែលកន្លងហួសទៅជាបញ្ហាពិតប្រាកដ ។ នេះវាធ្វើអោយមានការងាយស្រួលសំរាប់អនុវត្តន៏ជំនួយរបស់ព្រះជាម្ចាស់ក្នុងការជួយដោះស្រាយបញ្ហា ។

ព្រះជាម្ចាស់មិនចង់ឱ្យអ្នកប្រងើយកន្តើយជាមួយនឹងចំណង់របស់អ្នកនោះទេ ។ ប្រសិនបើអ្នកមានចំណង់ធ្វើអំពើបាបនៅខាងក្នុង អ្នកត្រូវតែផ្លាស់ប្តូរវាចេញ ។ ចំណង់វាដូចគ្នាទៅនឹងអាកប្បកិរិយារបស់អ្នកដែរ គឺយើងត្រូវរៀនពីកិច្ចការនេះទាំងពីរ ។ ឥឡូវនេះអ្នកបានក្លាយទៅជាគ្រីស្ទបរិស័ទហើយ អ្នកចាំបាច់ត្រូវតែវាយតំលៃកិច្ចការនេះដោយប្រុងប្រយត្ន័ និង ធ្វើការបង្កើតនូវចំណង់ដែលព្រះជាម្ចាស់ចង់ឱ្យអ្នកមាន ។

នៅ ២ ធីម៉ូថេ ផ្តល់ឱ្យយើងយ៉ាងច្រើននូវដំបូន្មានល្អៗអំពីចំណង់របស់យើង ។
**២ ធីម៉ូថេ ២:២២ ចូរគេចអោយផុតពីតណ្ហានៃយុវវ័យហើយខំប្រឹងប្រែងរកសេចក្តីសុចរិត ជំនឿ សេចក្តីស្រលាញ់ សេចក្តីសុខសាន្តជាមួយអស់អ្នកដែលគោរពព្រះអម្ចាស់ដោយចិត្តបរិសុទ្ធនោះវិញ ។** រៀនឱ្យមានចំណង់ចង់បាន ជំនឿ, សេចក្តីស្រលាញ់ និង សេចក្តីសុខសាន្ត ។

ទំនុកតម្កើង ៣៧ ផ្តល់នូវសេចក្តីសន្យាយ៉ាងល្អអំពីចំណង់របស់យើង ។
**ទំនុកតម្កើង ៣៧ : ៤-៥ ចូរស្វែងរកសុភមង្គលពីព្រះអម្ចាស់ ... នោះទ្រង់នឹងជួយអ្នក ។** ព្រះអង្គព្រួយបារម្ភពីតំរូវការនិងចំណង់របស់អ្នក ។ ព្រះអង្គសន្យាថាបំពេញតំរូវការរបស់អ្នក ទាំងអស់ ។ ទ្រង់ចង់បំពេញចំណង់នៃចិត្តរបស់អ្នកប្រសិនបើចិត្តរបស់អ្នកប្តេជ្ញាធ្វើអ្វីៗទៅតាមព្រះហឫទ័យរបស់ទ្រង់ ។

# ជំពូក ទី២
# ដំណើរការនៃការយកឈ្នះលើការល្បួង

គ្មានដំណោះស្រាយខាងមន្តអាគមន្តសំរាប់ការយកឈ្នះរាល់ការល្បួងដែលអ្នកប្រឈមមុខជានិច្ចជាកាលនោះទេ ប៉ុន្តែព្រះជាម្ចាស់បានសន្យាជួយអ្នកនៅពេលដែលអ្នកជួបការល្បួង ។ អ្នកក៏មានព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកដឹកនាំ និង ជាគ្រូរបស់អ្នកផងដែរ ។ អ្នកអាចរៀនទទួលយកជោគជ័យក្នុងការប្រឆាំងជាមួយនឹងការល្បួង ។ ដូច្នេះ តើគ្រីស្ត បរិស័ទថ្មីចាប់ផ្តើមនៅឯណា?

## ក. តើអ្នកឈរនៅឯណា?

តើអ្នកធ្លាប់ព្យាយាមដើរនៅលើរបង ឬក៏ ជញ្ជាំងឬទេ? ប្រសិនបើអ្នកធ្លាប់ធ្វើ អ្នកដឹងការលំបាកក្នុងការដើរនេះហើយ ជាពិសេសប្រសិនបើវាតូចចង្អៀតនោះ ។ គ្រីស្តបរិស័ទថ្មីខ្លះៗកំពុងព្យាយាមដើរនៅលើរបង ។ ពួកគេមិនទាន់បានសំរេចចិត្តពេញលេញនៅឡើយ ប្រសិនបើពួកគេចង់លះបង់សកម្មភាពដែលសប្បាយស៊ីគ្នាជាមួយនឹងអ្នកដែលកំពុងតែធ្វើអំពើបាបនោះ ។

ម្ខាងនៃរបងគឺជាជីវិតដែលព្រះជាម្ចាស់ចង់អោយកូនរបស់ទ្រង់រស់នៅ ។ ម្ខាងទៀតគឺជាកិច្ចការអាក្រក់ កំពុងល្បួងអ្នកអោយមក និង សប្បាយជាមួយនឹងការសប្បាយទាំងប៉ុន្មានដែលមានរយៈពេលតែមួយភ្លែតនោះ ។

គ្រប់គ្រីស្តបរិស័ទទាំងអស់ត្រូវតែធ្វើការសំរេចចិត្ត ។ អ្នកមិនអាចដើរនៅលើរបងអស់មួយជីវិតរបស់អ្នកបានទេ ។ អ្នកត្រូវតែជ្រើសរើសដើរតាមផ្លូវរបស់ព្រះជាម្ចាស់ ឬក៏ផ្លូវរបស់អារក្សសាតាំង ។ ប្រសិនបើអ្នកចង់មានជោគជ័យក្នុងការរៀនប្រឆាំងជាមួយការល្បួងរបស់សាតាំង អ្នកត្រូវតែប្តេជ្ញាចិត្តយ៉ាងពេញលេញដើរតាមផ្លូវរបស់ព្រះជាម្ចាស់ ។

យ៉ាកុប ៤:៧-៨ ផ្តល់នូវដំបូន្មានយ៉ាងច្បាស់លាស់នៅលើអ្វីដែលព្រះជាម្ចាស់ចង់អោយគ្រីស្តបរិសទ័ធ្វើនៅពេលដែលសាតាំងល្បួង ។

**យ៉ាកុប ៤:៧-៨**

**ដូច្នេះសូមបងប្អូនគោរពចុះចូលព្រះជាម្ចាស់ ហើយប្រឆាំងនឹងមារ នោះវាមុខជារត់ចេញឆ្ងាយពីបងប្អូនមិនខាន ។ សូមចូលទៅជិតព្រះជាម្ចាស់ នោះព្រះអង្គនឹងយាងមកជិតបងប្អូនវិញដែរ ។ មនុស្សបាបអើយ ចូរជំរះខ្លួនអោយបានបរិសុទ្ធទៅ! មនុស្សមានចិត្តពីរអើយ ចូរជំរះចិត្តគំនិតអោយបានស្អាតឡើង!**

**ជ្រើសរើសមួយ**

ខាងព្រះជាម្ចាស់

ខាងសាតាំង

ប្រសិនបើអ្នកជ្រើសរើសចូលទៅជិតព្រះជាម្ចាស់ ទ្រង់សន្យាថា ទ្រង់នឹងមកជិតអ្នកវិញ។ នេះចង្អុលបង្ហាញអោយឃើញបញ្ហាគន្លឹះដទៃទៀត ។ តើនៅក្នុងទិសដៅមួយណាដែលអ្នកកំពុងតែរំកិលទៅនោះ? នៅពេលដែលថ្ងៃចេះតែកន្លងហួសទៅ តើអ្នកនឹងខិតចូលទៅជិតព្រះជាម្ចាស់ឬ? ឬក៏ អ្នកប្រកាន់ភ្ជាប់ក្នុងការដើរនៅលើរបង?

ដូច្នេះជំហានដ៏ធំបំផុតដើម្បីយកឈ្នះលើការល្បួងគឺត្រូវជ្រើសរើសថាតើខាងមួយណាដែលអ្នកចង់នៅ-ខាងព្រះជាម្ចាស់ ឬក៏ ខាងអារក្សសាតាំង ។ នៅពេលដែលពួកគេបានធ្វើការសំរេចចិត្តនោះហើយ គំនិតបន្ទាប់មកទៀតពីរបៀបយកឈ្នះលើការល្បួងនឹងងាយស្រួលជាងដើម្បីធ្វើ ។

## ខ. តើនោះគឺជាការល្បួងឬ?

បញ្ហាធំបំផុតមួយដែលគ្រីស្តបរិស័ទថ្មីជាច្រើនកំពុងតែប្រឈមគឺយល់ដឹងនៅពេលណាដែលពួកគេកំពុងតែជួបការល្បួង ។ ជាច្រើនដងការល្បួងវាកន្លងហួសទៅហើយ មុននឹងពួកគេដឹងថា ពួកគេជួបប្រទះការល្បួង ។ នេះគឺជាគំរោងផែនការរបស់អារក្សសាតាំងទាំងអស់ ។ វាមិនមកដោយមានសញ្ញាធំៗបក់ចុះបក់ឡើងដោយនិយាយថា " **នេះគឺជាការល្បួង** ។ " ជាច្រើនដងវាថែមទាំងមិនស្គាល់ខ្លួនវាផង ។ វាគ្រាន់តែនិយាយថា " តើអ្នកចង់ ឬក៏ត្រូវការអ្វីមួយទេ? នេះគឺជាវិធីដ៏ងាយស្រួលដើម្បីទទួលវា។

**សាតាំងមិនបក់ចុះបក់ ឡើងនូវសញ្ញាធំៗនោះទេ**

ប្រសិនបើអ្នកចង់មានជ័យជំនះនៅក្នុងការប្រឆាំងនឹងការល្បួងរបស់អារក្សសាតាំង នោះមានន័យថា អ្នកត្រូវតែរៀនក្នុងការកត់សំគាល់ការល្បួងអោយបានលឿនពេលវាចាប់ផ្តើម ។ សូមអោយយើងគិតត្រឡប់ទៅអតីតកាលពីរបីថ្ងៃមុន ។ តើអ្នកអាចគិតដល់ពេលវេលាណាមួយនៅពេលដែលអ្នកជួបការល្បួងអោយធ្វើអំពើបាបឬទេ? តើអ្នកស្គាល់វាដោយរបៀបណា? តើលឿនប៉ុណ្ណាអ្នកបានស្គាល់វាថា ជាការល្បួងនោះ? តើមានពេលវេលាលំបាកក្នុងការស្គាល់ ថាតើគំនិតពិសេសណាមួយជាការល្បួងនោះទេ?

ព្រះជាម្ចាស់បានសន្យាជួយអ្នកនៅពេលដែលអ្នកជួបការល្បួង ។ ព្រះអង្គនឹងមានព្រះបន្ទូលមកកាន់អ្នកតាមរយៈមនសិការរបស់អ្នក និង ប្រាប់អ្នកពេលណាសាតាំងវានឹងព្យាយាមធ្វើអោយអ្នកធ្វើអំពើបាប ។ អ្នកចាំបាច់ត្រូវតែរៀនស្តាប់ព្រះជាម្ចាស់ដោយប្រុងប្រយត្ន័ និង យល់ដឹងនៅពេលណាព្រះអង្គនឹងមានព្រះបន្ទូលមកកាន់អ្នក ។

វិធីដទៃទៀតដែលអ្នកអាចដឹងនៅពេលដែលសាតាំងនឹងល្បួងអ្នកគឺត្រូវមើលឱកាសនៅខាងមុខរបស់អ្នក ។ សួរខ្លួនឯង " ប្រសិនបើខ្ញុំធ្វើកិច្ចការនេះ តើខ្ញុំធ្វើខុសនឹង

_______________ វិន័យព្រះជាម្ចាស់ឬ? ប្រសិនបើចំលើយ "បាទ" នោះអ្នកដឹងថាឱកាសនោះមិនមែនមកពីព្រះជាម្ចាស់នោះទេ ។

សំនួរដទៃទៀតដែលអ្នកអាចសួរខ្លួនឯងគឺ " ប្រសិនបើខ្ញុំធ្វើកិច្ចការនេះ តើវានឹងអោយខ្ញុំចូលទៅជិតព្រះជាម្ចាស់ឬទេ? ប្រសិនបើអ្នកគិតថា វានឹងនាំអោយអ្នកឃ្លាតឆ្ងាយពីព្រះជាម្ចាស់ នោះមានន័យថា អ្នកត្រូវពិនិត្យមើលអោយបានដិតដល់ ។ អ្នកប្រហែលជាផ្ទាំងស៊ីបនៃការល្បួងរបស់សាតាំងហើយ ។

រាល់គ្រិស្តបរិស័ទថ្មីទាំងអស់នឹងជាផ្ទាំងស៊ីបនៃការល្បួងជាច្រើនមកពីអារក្សសាតាំង ។ វានឹងធ្វើអ្វីៗទាំងអស់ដែលវាអាចធ្វើទៅបានដើម្បីបំផ្លាញជីវិតដែលអ្នកមាននៅក្នុងព្រះគ្រិស្ត ។ ដូច្នេះ វាមានសារសំខាន់ណាស់ដើម្បីបង្កើតអោយមានជំនាញនៅក្នុងការស្គាល់ការល្បួងអោយបានឆាប់ពេលវាមក ។ កិច្ចការនេះមានសារសំខាន់ណាស់ប្រសិនបើអ្នកចង់ជោគជ័យនៅក្នុងការប្រឆាំងទៅនឹងការល្បួង និង បំពេញតំរូវការ និងចំណង់របស់អ្នកទៅតាមផ្លូវរបស់ព្រះជាម្ចាស់ដែលទ្រង់ចង់អោយអ្នកបំពេញនោះ ។

នៅពេលដែលអ្នកយល់ដឹងថា អ្នកជួបប្រទះទៅនឹងការល្បួង នោះអ្នកអាចឆ្លើយតបនៅក្នុងវិធីមួយដែលនឹងជួយអ្នកប្រឆាំងទៅនឹងការលើកឡើងរបស់អារក្សសាតាំង ។ ឥឡូវនេះសូមអោយយើងមើលគំរូនៃការឆ្លើយតបចំពោះការល្បួងដែលនឹងជួយអ្នកអោយចូលទៅកាន់តែជិតព្រះជាម្ចាស់រាល់ពេលវេលាអ្នកជួបការល្បួង ។

## គ. តើអ្វីទៅគឺជាជំហានដើម្បីយកឈ្នះការល្បួង?

១. ទទួលស្គាល់ថា អ្នកជួបការល្បួង

២. បដិសេធន៍ ចំពោះការល្បួង

៣. ចាប់ផ្តើមនិយាយជាមួយព្រះជាម្ចាស់

៤. សួរខ្លួនឯង " តើតំរូវការអ្វីដែលសាតាំងកំពុងតែព្យាយាមបំពេញតំរូវការរបស់ខ្ញុំ? " ។

៥. ស្វែងរកផ្លូវរបស់ព្រះជាម្ចាស់ដើម្បីចេញឱ្យផុតពីការល្បួង

៦. បង្កើតគោលដៅដែលនឹងជួយបំពេញតំរូវការរបស់អ្នកតាមផ្លូវរបស់ព្រះជាម្ចាស់ ។

ឥឡូវនេះ សូមអោយយើងមើលនូវជំហាននីមួយៗទាំងនេះ ។ នៅពេលដែលអ្នកសិក្សាគំរូនៃការឆ្លើយតបនេះចំពោះការល្បួង សូមចងចាំទុកនូវការល្បួងថ្មីៗជាច្រើនដែល

អ្នកបានជួបប្រទះ ។ ព្យាយាមស្រមៃគិតពីរបៀបអ្នកអាចឆ្លើយតបចំពោះការល្បួងទាំងនោះជាមួយនឹងជំហានទាំង ៦ នេះ ។

## ១. ទទួលស្គាល់ថា អ្នកជួបការល្បួង

ប្រធានបទនេះត្រូវបានពិភាក្សារួចមកហើយនៅលើទំព័រទី ១២នៃសៀវភៅនេះ ។ នៅពេលដែលអ្នកជួបការល្បួង អ្នកអាចនិយាយទៅកាន់ខ្លួនអ្នកអោយខ្លាំង១ថា " ខ្ញុំជួបប្រទះការល្បួងអោយធ្វើអំពើបាបហើយ ។ " គ្រាន់តែឮខ្លួននិយាយពាក្យទាំងនេះអាចជួយអ្នកអោយបន្តទៅជំហានបន្ទាប់ទៀតនៅក្នុងគំរូនេះ ។ សាតាំងនឹងព្យាយាមបោកប្រាស់អ្នកអោយជឿថា អ្នកមិនមែនជួបការល្បួងអោយធ្វើអំពើបាបនោះទេ ។

## ២. សូមនិយាយពាក្យថា "ទេ" ចំពោះការល្បួង

នៅពេលដែលអ្នកទទួលស្គាល់ថា អ្នកបានជួបប្រទះទៅនឹងការល្បួងឱ្យធ្វើអំពើបាប អ្នកត្រូវតែធ្វើការសំរេចចិត្ត ។ អ្នកនឹងស្តាប់ការល្បួង ហើយ គិតអំពីដំណោះស្រាយដ៏ងាយស្រួលចំពោះតំរូវការរបស់អ្នក ឬក៏ អ្នកនឹងបដិសេធន៍កិច្ចការនេះចោល ។ ប្រសិនបើអ្នកបដិសេធន៍ អ្នកពិតជាឈរយ៉ាងរឹងមុំខាងព្រះជាម្ចាស់ ។ ប៉ុន្តែប្រសិនបើអ្នកនិយាយថា " ប្រហែល " ឬក៏ " ចាំអោយខ្ញុំគិតមើលអំពីកិច្ចការនេះសិន " នោះអ្នកបង្ហាញថា អ្នកនៅតែព្យាយាមដើរនៅលើរបងដដែល ។

នៅពេលដែលព្រះយេស៊ូជួបការល្បួងអោយធ្វើអំពើបាប ព្រះអង្គបដិសេធន៍គិតពីផែនការរបស់សាតាំងសំរាប់បំពេញតំរូវការរបស់ទ្រង់ ។ ព្រះយេស៊ូបានបដិសេធន៍រាល់ការល្បួងរបស់សាតាំង ។ អ្នកអាចធ្វើដូចអញ្ចឹងដែរ ។ ព្រះជាម្ចាស់បានសន្យាផ្តល់អោយអ្នកនូវអំណាចដែលអ្នកត្រូវការប្រឆាំងចំពោះរាល់ការល្បួង ។ ( សូមមើល ១ កូរិនថូស ១០:១៣ ) ។

កុំស្ទាក់ស្ទើរក្នុងការបដិសេធន៍ចំពោះរាល់ការល្បួងពីសាតាំង អ្នកបដិសេធន៍ចំពោះការល្បួងកាន់តែឆាប់ អ្នកកាន់តែមានការងាយស្រួលបន្តទៅជំហានបន្ទាប់ទៀត ។

វិធីដទៃទៀតក្នុងការនិយាយបដិសេធន៍ចំពោះការល្បួងគឺត្រូវចេញអោយឆ្ងាយពីអ្វី១ឬក៏ នរណាម្នាក់ដែលកំពុងតែបង្កអោយកើតមានឡើងការល្បួងនោះ ។ ប្រសិនបើអ្នកអាចប្តូរកន្លែង ឬក៏ រកកន្លែងណាផ្សេងទៀត ឬក៏ ចេញអោយឆ្ងាយពីអ្វីដែលកំពុងតែល្បួងអ្នក-ធ្វើវាភ្លាម! នៅក្នុងសញ្ញាចាស់ យ៉ូសែបបានធ្វើកិច្ចការនេះ នៅពេលដែលគាត់បានប្រឈមមុខការល្បួងដ៏លំបាកមួយ ។ ( សូមមើល កំណើតពិភពលោក ៣៩) សុភាសិត ៤:២៣-២៧ ផ្តល់នូវដំបូន្មានបន្ថែមខ្លះ១ទៀតដើម្បីគេចចេញពីការល្បួងខាង

ផ្លូវភេទ ។

នៅក្នុង ១ ថេស្សាឡូនិក ៥:២២ ចែងថា " ត្រូវជៀសចេញអោយផុតពីអំពើអាក្រក់គ្រប់បែបយ៉ាង " ។ ផ្លូវដ៏ងាយស្រួលបំផុតដើម្បីប្រឆាំងទៅនឹងការល្បួងខ្លះ គឺគ្រាន់តែធ្វើតាមការផ្តល់ដំបូន្មានរបស់ព្រះជាម្ចាស់នៅក្នុង ខគម្ពីរនេះ ។

### ៣. ចាប់ផ្តើមនិយាយជាមួយព្រះជាម្ចាស់

ត្រូវស្មោះត្រង់ជាមួយនឹងព្រះជាម្ចាស់ ។ ប្រាប់ព្រះអង្គត្រង់ៗនូវអារម្មណ៍របស់អ្នក ។ អ្នកប្រហែលជាយល់ឃើញថាផែនការរបស់អារក្សសាតាំងពេញទៅដោយការល្បួង ។ សូមកុំខ្លាចប្រាប់ដល់ព្រះជាម្ចាស់ពីអារម្មណ៍របស់អ្នក ។ សាតាំងចង់អោយតែអ្នកនិយាយតែជាមួយវាប៉ុណ្ណោះ ។ វាមិនចង់អោយអ្នកសួរព្រះជាម្ចាស់អោយផ្តល់ដំបូន្មានដល់អ្នកនោះទេ ។

**អ្នកមិនចាំបាច់បង្ហាញគស្តីគានអ្វីដល់សាតាំងនោះទេ ។ ព្រះយេស៊ូក៏មិនបានបង្ហាញអ្វីដែរ ។ សូមមើល ម៉ាថាយ ៤:១-១១ ។**

នៅពេលអ្នកអធិស្ឋានទៅព្រះជាម្ចាស់ សូមនាំការសន្យារបស់ទ្រង់ចូលទៅក្នុងការសន្ទនារបស់អ្នក ។ កិច្ចការនេះនឹងជួយអ្នកអោយនឹកឃើញឡើងវិញនូវអ្វីដែលព្រះអង្គបានសន្យាធ្វើសំរាប់អ្នក ។ សេចក្តីសន្យារបស់អ្នកព្រះជាម្ចាស់អាចលើកទឹកចិត្តអ្នកផងដែរអោយរកឃើញវិធីរបស់ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការ និង ចំណង់របស់អ្នក ។ សូមលើកឡើងអត្ថបទគម្ពីរដែលទាក់ទងទៅនឹងការល្បួង ។ នេះគឺជាអ្វីដែលព្រះយេស៊ូបានធ្វើនៅពេលដែលព្រះអង្គបានជួបការល្បួង ។

សូមអោយព្រះជាម្ចាស់ផ្តល់អោយអ្នកនូវចំណង់ និង អំណាចដើម្បីប្រឆាំងទៅនឹងនឹងការល្បួង ។ សូមរក្សាការនិយាយទៅកាន់ព្រះជាម្ចាស់នៅពេលដែលអ្នកធ្វើតាមជំហានដែលនៅសេសសល់នៃគំរូនេះសំរាប់ការប្រឆាំងការល្បួង ។

### ៤. សួរខ្លួនឯង " តើតំរូវការអ្វីដែលសាតាំងកំពុងតែព្យាយាមបំពេញតំរូវការរបស់ខ្ញុំ? "

សាតាំងតែងតែធ្វើអោយអ្នកចាប់អារម្មណ៍ ឬក៏ ចំណង់ដែលអ្នកមាន ។ ព្យាយាមដោះស្រាយនូវអ្វីជាតំរូវការ និង ចំណង់អោយបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ នៅពេលដូចគ្នានេះ អ្នកចាប់ផ្តើមគិតអំពីការបញ្ចប់លទ្ធផលនៃការធ្វើតាមវិធីសាតាំងនេះ ។ សាតាំងមិនចង់អោយអ្នកគិតអំពីលទ្ធផលដែលខូចខាតនៅថ្ងៃស្អែក ឬក៏សប្តាហ៍ក្រោយនោះទេ ។ វាគ្រាន់តែចង់អោយអ្នកគិតអំពីសេចក្តីសប្បាយ ដែលអ្នកនឹង

ពិសោធន៍ឥឡូវនេះដោយបំពេញតំរូវការ និង ចំណង់តាមផ្លូវរបស់វា ។

លទ្ធផលបញ្ចប់នៃគ្រប់ទាំងការល្បួងមកពីអារក្សសាតាំងគឺអំពើបាប ។ យ៉ាកុប ១:១៤-១៦ ពន្យល់ពីរបៀបដំណើរការនេះកើតឡើង ។

**យ៉ាកុប ១:១៤-១៦ ម្នាក់ៗជួបនឹងការល្បួងមកតែពីចិត្តលោភលន់របស់ខ្លួនឯងផ្ទាល់ទាក់ទាញ និង លួងលោមបញ្ឆោតប៉ុណ្ណោះ ។ ចិត្តលោភលន់រមែងតែងតែបង្កើតអំពើបាប លុះដល់អំពើបាបចំរើនដល់កំរិតហើយក៏បណ្តាលអោយស្លាប់ . . . ។**

ប្រសិនបើអ្នកស្គាល់តំរូវការ និង ចំណង់ដែលសាតាំងកំពុងតែព្យាយាមអោយអ្នកបំពេញនោះ អ្នករៀបចំខ្លួនជាស្រេចដើម្បីធ្វើនៅជំហានបន្តទៀត ។

## ៥. ស្វែងរកផ្លូវរបស់ព្រះជាម្ចាស់ដើម្បីចេញឱ្យផុតពីការល្បួង

ព្រះគម្ពីរពោរពេញទៅដោយដំបូន្មានពីរបៀបដែលព្រះជាម្ចាស់ចង់អោយអ្នកបំពេញតំរូវការ និង ចំណង់ពិតប្រាកដរបស់អ្នក ។ បញ្ហាតែមួយគត់ប្រហែលជាការស្វែងរកនូវអ្វីដែលព្រះជាម្ចាស់អោយអ្នកធ្វើនៅក្នុងស្ថានភាពជាក់លាក់ណាមួយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានពេលជាច្រើន នៅពេលដែលអ្នកជួបការល្បួង អ្នកស្វែងរកភាពស្របគ្នាមួយដើម្បីស្វែងរកមើលអត្ថបទគម្ពីរដែលមានពី ១០ទៅ ១៥ ខគម្ពីរដែលទាក់ទងទៅនឹងតំរូវការ និង ចំណង់ដែលអ្នកកំពុងតែជួបការល្បួងអោយបំពេញ ។ យើងនឹងមើលអោយកាន់តែជិតនៅក្នុងសៀវភៅនេះពេលក្រោយពីរបៀបដែលអ្នកអាចត្រៀមខ្លួនសំរាប់ការល្បួង ។

យើងមានការសន្យារបស់ព្រះជាម្ចាស់ថា ព្រះអង្គនឹងផ្គត់ផ្គង់តំរូវការរបស់យើង ភីលីព ៤:១៩ ចែងថា " ព្រះរបស់ខ្ញុំនឹងបំពេញតំរូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ ។ " សាតាំងនឹងព្យាយាមបោកប្រាស់អ្នកអោយជឿថា ចំណង់របស់អ្នក ខ្លះគឺជាតំរូវការ ។ ប៉ុន្តែព្រះជាម្ចាស់បានសន្យាផងដែរថានឹងបំពេញចំណង់របស់អ្នកប្រសិនបើអ្នកប្តេជ្ញាចិត្តយ៉ាងពិតប្រាកដជាមួយនឹងព្រះជាម្ចាស់ ។

**ទំនុកតម្កើង ៣៧:៤-៥ ចូរស្វែងរកសុភមង្គលពីព្រះជាម្ចាស់ នោះព្រះអង្គនឹងប្រោសប្រទាននូវអ្វីៗដែលអ្នកប្រាថ្នាចង់បាន ។ ចូរផ្ញើជីវិតលើព្រះអង្គនោះទ្រង់នឹងជួយអ្នក ។**

សំនួរដែលអ្នកត្រូវតែសួរខ្លួនឯង នៅពេលដែលសាតាំងកំពុងតែល្បួងអ្នកអោយបំពេញចំណង់របស់អ្នកនៅក្នុងជីវិតគឺ " តើការបំពេញចំណង់របស់ខ្ញុំស៊ីគ្នាដោយរបៀប

ណាទៅនឹងអាទិភាពរបស់ព្រះជាម្ចាស់សំរាប់ខ្ញុំដែរឬទេ? " តើអ្វីដែលសំខាន់បំផុតនៅក្នុងចំនុចនេះសំរាប់ជីវិតរបស់ខ្ញុំ? វាងាយស្រួលណាស់ក្នុងការចំណាយពេលវេលា ទាំងអស់របស់យើងក្នុងការយកចិត្តទុកដាក់នូវចំណង់ផ្ទាល់ខ្លួន និង សេចក្តីប៉ងប្រាថ្នារបស់យើងដែលវាអាចអោយយើងភ្លេចអំពីតំរូវការរបស់អ្នកដទៃ ។ សាតាំងចង់អោយអ្នកក្លាយទៅជាមនុស្សអត្មានិយម ។ ព្រះជាម្ចាស់ចង់ឃើញអ្នកមានសកម្មភាព ទាក់ទៅនឹងការជួយអ្នកដទៃទៀតក្រៅពីខ្លួនជួយខ្លួនឯងផ្ទាល់ ។ ពេលណាមានការល្បួង ព្រះអង្គបានសន្យាជួយអ្នកអោយរកផ្លូវចេញពីការល្បួងបាន ។

**១ កូរិនថូស ១០:១៣ គ្មានការល្បួងណាមួយកើតមកដល់បងប្អូនក្រៅពីការល្បួងដែលមនុស្សលោកតែងជួបប្រទះនោះឡើយ ។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ទ្រង់មិនបណ្តោយអោយមារល្បួងបងប្អូនហួសពីកម្លាំងបងប្អូនទេ ប៉ុន្តែនៅពេលបងប្អូនជួបការល្បួង ព្រះអង្គនឹងប្រទានមធ្យោបាយអោយបងប្អូនចេញរួច និង អោយបងប្អូនអាចទ្រាំទ្របាន ។**

អ្នកប្រហែលជាមិនស្គាល់នូវផ្លូវដ៏ល្អបំផុតក្នុងការបំពេញតំរូវការរបស់អ្នកតាមផ្លូវរបស់ព្រះជាម្ចាស់ ប៉ុន្តែអ្នកអាចដឹងច្បាស់ថានៅក្នុងគ្រប់ទាំងការល្បួង ព្រះជាម្ចាស់នឹងជួយអ្នកអោយរកផ្លូវចេញពីការល្បួងនេះ ។ ព្រះជាម្ចាស់ទ្រង់តែងតែរក្សានូវការសន្យារបស់ទ្រង់ ។ ប៉ុន្តែប្រសិនបើអ្នកចង់ធ្វើអោយវាកាន់តែលំបាកសំរាប់សាតាំងក្នុងការល្បួងអ្នកនៅក្នុងកន្លែងពិសេសណាមួយក្នុងពេលអនាគត នោះអ្នកត្រូវតែរកអោយឃើញនូវផ្លូវរបស់ព្រះជាម្ចាស់ដើម្បីបំពេញតំរូវការ ឬក៏ ចំណង់នោះ ហើយបន្ទាប់មកបន្តធ្វើនូវជំហានបន្ទាប់ទៀត ។

**ថតចំលងកាតនេះ និង រក្សាទុកវារហូតទាល់តែអ្នករៀនផ្លូវជំហានទាំងនេះ**

ជំហាន ៦ យ៉ាងដើម្បីយកជំនះលើការល្បួង
១.ទទួលស្គាល់ថា អ្នកជួបការល្បួង
២.បដិសេធនឹងចំពោះការល្បួង
៣.ចាប់ផ្តើមនិយាយជាមួយព្រះអង្គ
៤.សួរខ្លួនឯង " តើតំរូវការអ្វីដែលសាតាំងកំពុងតែព្យាយាមបំពេញតំរូវការរបស់ខ្ញុំ? "
៥.ស្វែងរកផ្លូវរបស់ព្រះជាម្ចាស់ដើម្បីចេញអោយផុតពីការល្បួង
៦.បង្កើតគោលដៅដែលនឹងជួយបំពេញតំរូវការរបស់អ្នកតាមផ្លូវរបស់ព្រះជាម្ចាស់

## ៦. បង្កើតគោលដៅដែលនឹងជួយអ្នកអោយបំពេញសេចក្តីត្រូវការរបស់អ្នកទៅតាមផ្លូវរបស់ព្រះជាម្ចាស់

តើកិច្ចការជាក់ស្តែងអ្វីខ្លះដែលអ្នកអាចធ្វើដើម្បីចាប់ផ្តើមបំពេញតំរូវការ ឬក៏ ចំណង់របស់អ្នកទៅតាមផ្លូវរបស់ព្រះជាម្ចាស់? ដំបូងស្វែងរក ខគម្ពីរខ្លះៗដែលនិយាយអំពីពីរបៀបដែលព្រះជាម្ចាស់ចង់អោយអ្នកឆ្លើយតបទៅនឹងតំរូវការ និង ចំណង់នោះ ។ ទន្ទេញ ខគម្ពីរ ហើយបន្ទាប់មកចាប់ផ្តើមបង្កើតគោលដៅដ៏សាមញ្ញមួយដែលអ្នកអាចបំពេញនៅក្នុងរយៈពេលមួយថ្ងៃ។ អ្នកប្រហែលជាត្រូវការជំនួយខ្លះនៅត្រង់ចំនុចនេះ ។ សូមកុំមានការភ័យខ្លាចក្នុងការពិភាក្សាកិច្ចការនេះជាមួយនឹងមិត្តភ័ក្តិគ្រីស្ទបរិស័ទដទៃទៀតរបស់អ្នក ។ យោងទៅតាមអ្វីដែល ១ កូរិនថូស ១០:១៣ចែងថា គាត់ប្រហែលជា

ប្រឈមមុខទៅនឹងការល្បួងដូចគ្នាដែលមនុស្សលោកតែងតែជួបប្រទះនោះ ។

អ្នកអាចចាប់ផ្តើមធ្វើការដោះស្រាយនូវគោលដៅទាំងនេះភ្លាមៗ ។ អ្នកចាប់ផ្តើមកាន់តែឆាប់សាតាំងនឹងមានការលំបាកកាន់តែខ្លាំងក្នុងការល្បួងអ្នក ។ អ្នកត្រូវតែបញ្ជាក់ឡើងវិញម្តងទៀតនូវការប្តេជ្ញាចិត្តរបស់អ្នកក្នុងការប្រឆាំងទៅនឹងការល្បួងរបស់សាតាំង ។ នៅពេលដែលអ្នកបន្តចូលទៅជិតព្រះជាម្ចាស់ អ្នកនឹងមានការងាយស្រួលស្គាល់ពីរបៀបដែលព្រះជាម្ចាស់ចង់ឱ្យអ្នកបំពេញតំរូវការ និង ចំណង់ដែលអ្នកមាន ។

ជំហានទាំង៦ នេះអាចជួយអ្នកឱ្យមានជោគជ័យនៅក្នុងការយកឈ្នះលើការល្បួងឱ្យធ្វើអំពើបាបបាន ។ ប៉ុន្តែសូមកុំព្យាយាមធ្វើតាមដោយកំលាំងផ្ទាល់ខ្លួនរបស់អ្នក ។ សូមព្រះជាម្ចាស់ផ្តល់អោយនូវចំណង់ និងអំណាចដល់អ្នកក្នុងការយកឈ្នះលើការល្បួងនីមួយៗដែលអ្នកប្រឈមមុខ ។ អ្នកអាចរៀននិយាយពីបទពិសោធន៍ " ខ្ញុំអាចទ្រាំទ្របានទាំងអស់ដោយរួមជាមួយព្រះអង្គដែលប្រទានកម្លាំងអោយខ្ញុំ" ភីលីព ៤:១៣ ។ អ្នកយកជ័យជំនះលើការល្បួងកាន់តែច្រើន ជីវិតជាគ្រីស្តបរិស័ទរបស់អ្នកនឹងកាន់តែរឹងមាំឡើង ។

# ជំពូក ទី៣

# របៀបរៀបចំខ្លួនសំរាប់ការល្បួង

អ្នកអាចប្រាកដថា ការល្បួងអោយធ្វើអំពើបាបនឹងមកនៅក្នុងជីវិតរបស់អ្នក ។ គ្រប់គ្រីស្តបរិស័ទទាំងអស់នឹងបន្តជួបការល្បួងអោយធ្វើអំពើបាបរហូតទាល់តែដល់ថ្ងៃគាត់ស្លាប់ ទោះជា ប្រភេទ និង ឱកាសនៃការល្បួងអាចដូរក៏ដោយ ។ សូមអោយយើងមើលកាន់តែជិតនូវកិច្ចការខ្លះៗដែលអ្នកអាចធ្វើដើម្បីរៀបចំខ្លួនអ្នកសំរាប់កិច្ចការដែលនឹងមកចូលក្នុងជីវិតរបស់អ្នក ។

## ក. ការចូលទៅជិតព្រះជាម្ចាស់

ផ្លូវដែលសំខាន់បំផុតដើម្បីរៀបចំគ្មានទំនាក់ទំនងដោយផ្ទាល់ចំពោះការល្បួងជាក់លាក់ណាមួយនោះទេ ។ យ៉ាកុប ៤:៧ និង ៨ ពន្យល់អ្វីដែលត្រូវធ្វើ ពេលសាតាំងល្បួងអ្នកអោយធ្វើអំពើបាប ។

**យ៉ាកុប ៤:៧-៨ ដូច្នេះសូមបងប្អូនគោរពចុះចូលព្រះជាម្ចាស់ហើយប្រឆាំងនឹងមារ នោះវាមុខជារត់ចេញឆ្ងាយពីបងប្អូនមិនខាន ។ សូមចូលទៅជិតព្រះជាម្ចាស់ នោះព្រះអង្គនឹងយាងមកជិតបងប្អូនវិញដែរ ។ មនុស្សបាបអើយ ចូរជំរះខ្លួនអោយបានបរិសុទ្ធទៅ! មនុស្សមានចិត្តពីរអើយ ចូរជំរះចិត្តគំនិតអោយបានស្អាតឡើង! ។**

ប្រឆាំងនឹងការវាយប្រហារ-គឺចូលទៅជិតព្រះជាម្ចាស់

គន្លឹះនៅក្នុងការប្រឆាំងទៅនឹងការវាយប្រហាររបស់អារក្សសាតាំងគឺចូលទៅជិតព្រះជាម្ចាស់ ។ នេះគឺជាផ្លូវមួយដ៏សំខាន់ផងដែរដើម្បីរៀបចំសំរាប់ការល្បួងដែលនៅមុខអ្នក ។ សេចក្តីសន្យារបស់ព្រះជាម្ចាស់នៅក្នុង ភីលីព ៤:១៣ បញ្ជាក់យ៉ាងច្បាស់ថា " ខ្ញុំអាចទ្រាំទ្របានទាំងអស់ដោយរួមជាមួយនឹងព្រះអង្គដែលប្រទានកម្លាំងអោយខ្ញុំ ។" ព្រះជាម្ចាស់នឹងផ្គត់ផ្គង់អ្នកក្នុងការប្រឆាំងគ្រប់ការល្បួង នៅពេលដែលអ្នកចូលទៅជិតព្រះជាម្ចាស់ ។

**អេភេសូ ៦:១០ មួយវិញទៀតចូរទាញយកកម្លាំង ដោយរួមជាមួយនឹងព្រះអម្ចាស់ និងដោយសារព្រះចេស្តាដ៏ខ្លាំងក្លារបស់ព្រះអង្គ ។ (១១) ចូរបងប្អូនប្រដាប់ខ្លួនដោយគ្រឿងសាស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ដើម្បីអាចតតាំងនឹងល្បិចរបស់មារ ។**

ប្រសិនបើអ្នកចង់មានកំលាំងរបស់ព្រះជាម្ចាស់នៅខាងក្នុងនៅពេលអ្នកមាន

ការប្រឈមមុខការល្បួង នោះអ្នកនឹងត្រូវតែមានកំលាំងនេះមុននឹងការល្បួងចូលមក ។ អ្នកលេងបាល់បោះមិនរងចាំរហូតទាល់តែរដូវលេងកីឡានេះមកដល់ហើយចាប់ផ្តើមហាត់នោះទេ។ គឺគាត់ហាត់ និង អនុវត្តន៍អស់រយៈពេលជាច្រើនសប្តាហ៍មុននឹងចាប់ផ្តើមលេង។ មែនហើយ គឺគាត់ត្រូវតែសំរេចចិត្តដើម្បីរៀបចំខ្លួនគាត់ផ្ទាល់ ។ នៅពេលដែលគាត់បានចូលរួមនៅក្នុងក្រុម គាត់បានដឹងថា នៅទីនោះនឹងមានពេលវេលានៃការហ្វឹកហ្វឺនយ៉ាងច្រើន ហើយលំបាក ។ ប៉ុន្តែ ការរៀបចំទាំងអស់នឹងមានប្រយោជន៍នៅពេលដែលកីឡាបានចាប់ផ្តើម ហើយគាត់នឹងអាចជួយក្រុមរបស់គាត់អោយមានជ័យជំនះ ។

ប្រសិនបើអ្នកចង់មានជ័យជំនះនៅក្នុងការល្បួងអោយធ្វើអំពើបាប អ្នកចាំបាច់ត្រូវតែចំណាយពេលវេលាអានព្រះគម្ពីរ និង អធិស្ឋានរាល់ថ្ងៃ ដូច្នេះអ្នកនឹងមានកំលាំងខាងព្រលឹងវិញ្ញាណដែលអ្នកត្រូវការ ។ វាសំខាន់ផងដែរដើម្បីដឹងប្រាកដថាការប្តេជ្ញាចិត្តរបស់អ្នកចំពោះព្រះគ្រីស្តត្រូវតែរឹងមាំ ។ មនុស្សដែលកំពុងតែព្យាយាមសំរេចចិត្តថាតើត្រូវក្លាយជាគ្រីស្តបរិស័ទឬក៏ មិនត្រូវក្លាយនោះនឹងមានការពិបាកក្នុងការអប់រំខ្លួនគាត់អោយសិក្សាព្រះគម្ពីរ និង អធិស្ឋាន ។ នៅពេលដែលអ្នកបានប្តេជ្ញាចិត្តយ៉ាងពេញលេញចំពោះព្រះគ្រីស្ត វាងាយស្រួលជាងប្រមូលកំលាំងរបស់អ្នកទាំងមូលអោយរៀបចំសំរាប់ការល្បួងដែលវានឹងមក ។

ព្រះជាម្ចាស់បានសន្យាការពារគ្រប់គ្រីស្តបរិស័ទនៅពេលដែលគាត់ប្រឈមមុខការល្បួងអោយធ្វើអំពើបាបផងដែរ ។

**១ កូរិនថូស ១០:១៣ គ្មានការល្បួងណាមួយកើតមកដល់បងប្អូនក្រៅពីការល្បួងដែលមនុស្សលោកតែងជួបប្រទះនោះឡើយ ។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ទ្រង់មិនបណ្តោយអោយមារល្បួងបងប្អូនហួសពីកម្លាំងបងប្អូនទេ ប៉ុន្តែនៅពេលបងប្អូនជួបការល្បួង ព្រះអង្គនឹងប្រទានមធ្យោបាយអោយបងប្អូនចេញរួច និង អោយបងប្អូនអាចទ្រាំទ្របាន ។**

**រៀនពីរបៀបគេចចេញរបស់ព្រះជាម្ចាស់ដើម្បីប្រុងប្រៀបខ្លួនមុនការល្បួងលេចឡើង។**

គន្លឹះដើម្បីយល់ដឹងនៅទីនេះគឺថា ព្រះជាម្ចាស់នឹងប្រទានមធ្យោបាយអោយអ្នកចេញរួចគ្រប់ការល្បួងដែលមករកអ្នក ។ ដើម្បីរៀបចំសំរាប់ការល្បួងទាំងឡាយ អ្នកចាំបាច់ត្រូវតែរៀនពីផ្លូវងាកចេញពីសាតាំងរបស់ព្រះជាម្ចាស់ ។ ព្រះគម្ពីរផ្តល់នូវការណែនាំយ៉ាងច្បាស់ពីរបៀបបំបាត់ចោលការល្បួង ។ នៅក្នុងកំណើតពិភពលោក ៣៩ យ៉ូសែបបានរត់ចេញពីមនុស្សដែលបានល្បួងគាត់អោយធ្វើអំពើបាប ។ នោះអាចជាផ្លូវរបស់ព្រះជាម្ចាស់សំរាប់អ្នកកុំអោយធ្លាក់ទៅក្នុងអំពើបាប ។ នៅឱកាសដទៃទៀត ផ្លូវរបស់ព្រះជាម្ចាស់អាច

ព្រះជាម្ចាស់តែងតែមានព្រះបន្ទូលនៅក្នុងសំលេងមួយដែលមិនសូវឮ ។

ប្រឆាំងអារក្សសាតាំង និង ឈរយ៉ាងរឹងមាំ ប្រកាសសេចក្តីសន្យារបស់ព្រះជាម្ចាស់ ផ្តល់អោយអ្នកនូវកំលាំងដើម្បីប្រឆាំងទៅនឹងការល្បួងអោយធ្វើអំពើបាប ។

ការរៀនវិធីនៃការឆ្លើយតបរបស់ព្រះជាម្ចាស់ចំពោះការល្បួងនីមួយៗបង្កើតបញ្ហាដទៃទៀត ។ អ្នកចាប់ផ្តើមត្រូវតែរៀនស្តាប់ព្រះជាម្ចាស់ ។ ព្រះជាម្ចាស់កំរនឹងមានព្រះបន្ទូលខ្លាំងៗរឺជាសំលេងលាន់ឮខ្លាំងក្នុងការផ្តល់អោយយើងនូវដំបូន្មាននោះទេ ។ ព្រះអង្គតែងតែមានព្រះបន្ទូលនៅក្នុងសំលេងមួយដែលមិនសូវឮគឺនៅក្នុងមនសិការរបស់អ្នក ។

**កាឡាទី ៥:១៦**

**ចូររស់នៅអោយស្របតាមព្រះវិញ្ញាណ នោះបងប្អូននឹងមិនបំពេញតាមបំណងចិត្តលោភលន់របស់លោកីយ៍ទៀតឡើយ ។**

ព្រះវិញ្ញាណដ៏វិសុទ្ធនឹងណែនាំអ្នកឱ្យយល់ដឹងពីសេចក្តីពិតផងដែរនៅពេលអ្នកសិក្សាព្រះបន្ទូលរបស់ទ្រង់ និង អធិស្ឋាន ។ ប្រសិនបើមានការល្បួងពិសេសណាមួយដែលផ្តល់អោយអ្នកនូវទុក្ខលំបាកជាច្រើន នោះសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញអ្នកនូវផ្លូវរបស់ព្រះជាម្ចាស់ដើម្បីយកឈ្នះលើវា ។ ការរៀនស្តាប់ព្រះជាម្ចាស់ប្រហែលជាមិនងាយស្រួលសំរាប់អ្នកនោះទេ ។ ប៉ុន្តែព្រះជាម្ចាស់ទ្រង់ស្មោះត្រង់ និង អត់ធ្មត់ចំពោះយើង ។ នៅពេលដែលអ្នកចូលទៅជិតព្រះជាម្ចាស់ វានឹងងាយស្រួលជាងឮអ្វីដែលព្រះអង្គនឹងមានព្រះបន្ទូល ។

## ខ. បំពេញគំរូចការរបស់អ្នកនៅក្នុងផ្លូវរបស់ព្រះជាម្ចាស់

គ្រីស្តបរិស័ទថ្មីជាច្រើនមានការល្បួងយ៉ាងហោចណាស់មួយដែលអារក្សប្រើពីមួយថ្ងៃទៅមួយថ្ងៃដើម្បីព្យាយាមអោយពួកគេធ្វើអំពើបាប ។ ប្រសិនបើអ្នកមានការល្បួងមួយនៅក្នុងចំណោមការល្បួងទាំងនេះ នោះវាប្រហែលជាមានប្រយោជន៍សំរាប់អ្នកអោយមើលកាន់តែជិតថែមទៀត ។

### ១. ការបង្ហាញអោយដឹងពីការល្បួងដ៏ធំរបស់អ្នក

អ្នកអាចយោងទៅកិច្ចការដែលអ្នកបានធ្វើនៅគំរោង ទី ២ *ការបង្ហាញឱ្យដឹងពីការល្បួង* នៅក្នុងគំរោងនេះ អ្នកបានស្គាល់ និង ពិនិត្យការល្បួងថ្មីៗខ្លះរបស់អ្នក ។ អ្នកអាចចំណាយពេលខ្លះឥឡូវនេះដើម្បីឆ្លើយសំនួរដូចគ្នាទាំងនោះយោងទៅតាមការល្បួងដែលអ្នកប្រឈមមុខបំផុត ។ សូមរកមើលប្រសិនបើមានគំរូខ្លះចំពោះការល្បួងនេះ ។ តើវាមកនៅក្នុងពេលវេលាពិសេសណាមួយឬទេ ឧទាហរណ៍ បន្ទាប់ពីញ៉ាំអាហាររួចវាមក?

ឬក៏ វាមកនៅពេលអ្នកនៅក្នុងកន្លែងពិសេសណាមួយ ឬក៏ នៅជិតមនុស្សជាក់លាក់ណាម្នាក់? ព័ត៌មាននេះអាចជួយចង្អុលបង្ហាញវិធីមួយដ៏សមរម្យដែលអ្នកអាចរៀបចំសំរាប់ការល្បួងនេះ ។

សុខ ទើបតែក្លាយជាគ្រីស្ទបរិស័ទពីរបីថ្ងៃមុន ។ គាត់ចង់ឈប់ជក់បារី ប៉ុន្តែគាត់មានការពិបាកក្នុងការបញ្ឈប់វា ។ បន្ទាប់ពីញ៉ាំអាហាររួច ការល្បួងអោយជក់បារីមានខ្លាំងណាស់ ។ តើហេតុអ្វី? ពីព្រោះដោយសារតែគាត់ទម្លាប់ជក់រាល់ពេលញ៉ាំអាហាររួច ។ សុខនិយាយថា " វាបានជួយខ្ញុំអោយសំរាកស្រួល " ។ វាដូចជាបង្អែមមួយដ៏ឆ្ងាញ់អញ្ចឹង វាធ្វើឱ្យខ្ញុំឆ្អែត ។ "

ប្រហែលជាអ្នកមិនអាចរកឃើញគំរូទៀងទាត់ណាមួយ នៅពេលការល្បួងដ៏ធំកើតឡើង ។ ប្រសិនបើដូច្នោះមែន សូមចំណាយពេលវេលាពីរបីថ្ងៃខាងមុខសរសេរចូលរាល់ពេលដែលការល្បួងមកដល់ ។ អ្នកអាចប្រើសំនួរដូចគ្នាដែលមាននៅក្នុងគំរោង ទី ២ នៅក្នុងការណែនាំការសិក្សា ។

**២. ការបង្ហាញឱ្យដឹងសេចក្តីត្រូវការដែលសាតាំងកំពុងតែព្យាយាមឱ្យអ្នកបំពេញ**

នៅពេលដែលអ្នកមានរូបភាពច្បាស់លាស់នៃការល្បួងដែលសាតាំងនឹងប្រើច្រើនបំផុតទៅលើអ្នក វាដល់ពេលចាប់ផ្តើមរៀបចំសំរាប់កិច្ចការនេះហើយ ។ ព្យាយាមដោះស្រាយអ្វីជាតំរូវការ និង ចំណង់ដែលសាតាំងកំពុងតែព្យាយាមអោយអ្នកបំពេញនៅក្នុងជីវិតរបស់អ្នក ។

ការល្បួងរបស់សុខអោយជក់បារីនោះមិនមែនជាការងាយស្រួលក្នុងការវាយតំលៃនៅក្នុងចំនុចនេះនោះទេ ។ អារម្មណ៍ពេញបរិបូរណ៍ដែលគាត់មានពិសោធន៍នៅពេលដែលគាត់បានជក់បារីបន្ទាប់ការញ៉ាំអាហារនោះប្រហែលជាស៊ីគ្នានៅក្នុងផ្នែក " ចំណង់ " ។ យើងបានបញ្ជាក់ពីខាងលើថា សាតាំងល្បួងយើងអោយបំពេញតំរូវការ ឬក៏ ចំណង់នៅក្នុងជីវិតរបស់យើង ។ ប៉ុន្តែ មានតំរូវការដទៃទៀតដែលមិនមែនជាការជក់បារីនឹងបំពេញជីវិតរបស់សុខដែលគាត់មិនទាំងយល់ដឹងផង ។ ឧទាហរណ៍ ការជក់បារីប្រហែលជាវិធីសំរាប់អោយគាត់សំរាក ។ ប្រសិនបើសុខយល់ដឹងថា មានគេធ្វើអោយគាត់ក្តៅក្រហាយឥឡូវនេះល្បួងអោយគាត់ជក់បារីនៅពេលនោះ ប្រហែលជាគាត់អាចសន្និដ្ឋានថា ការជក់បារីជួយបំពេញតំរូវការនោះនៅក្នុងជីវិតរបស់គាត់នៅក្នុងអតីតកាល ។

សំរាប់សុខគន្លឹះដើម្បីយកជ័យជំនះការល្បួងនេះគឺត្រូវស្វែងរកវិធីដទៃទៀតក្នុងការ

ការបំពេញចំណង់ និង តំរូវការទាំងនោះ ។ នៅពេលដែលអ្នករកឃើញផ្លូវរបស់ព្រះជាម្ចាស់ ក្នុងការសំរាក និង មានអារម្មណ៍ថាពេញបរិបូរណ៍ ដែលធ្វើអោយការញុំាអាហាររបស់គាត់សប្បាយរីករាយណាស់ គាត់បិទដំណោះស្រាយសំរាប់ការល្បួងនោះ ។ ឥឡូវនេះជំហានដែលធំបំផុតនោះគឺបំពេញតំរូវការនោះតាមផ្លូវរបស់ទ្រង់រាល់ពេល ។

នៅទំព័រ ទី ៧-៨នៅក្នុងសៀវភៅនេះ យើងបានពិភាក្សាប្រភេទខុសគ្នាខ្លះៗនៃតំរូវការដែលយើងទាំងអស់គ្នាមាន ។ អ្នកអាចរំលឹកឡើងវិញនូវចំនុចនោះឥឡូវនេះ និង សួរខ្លួនឯងនូវសំនួរនេះ : " តើតំរូវការមួយណានៅក្នុងចំណោមតំរូវការទាំងនេះ ដែលពិបាកបំពេញនោះ? " អ្នកមិនត្រូវរងចាំរហូតទាល់តែសាតាំងល្បួងអ្នកអោយរកឃើញនូវការបំពេញចិត្តតាមផ្លូវរបស់វានោះទេ ។ អ្នកដឹងថាអ្នកមានតំរូវការ ត្រូវប្រញាប់ចាប់ផ្តើមស្វែងរកផ្លូវរបស់ព្រះជាម្ចាស់ដើម្បីដោះស្រាយជាមួយនឹងតំរូវការនោះ ។ វិធីមួយដែលល្អបំផុតដើម្បីការពារសាតាំងកុំអោយល្បួងអ្នកនៅក្នុងកន្លែងខ្លះៗគឺត្រូវបំពេញតំរូវការនោះតាមផ្លូវរបស់ព្រះជាម្ចាស់មុន ។

**ទទួលស្គាល់ផ្លូវរបស់ព្រះជាម្ចាស់ក្នុងការដោះស្រាយតំរូវការរបស់អ្នក ។**

## ៣. រកអោយឃើញផ្លូវរបស់ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការអ្នក

ព្រះជាម្ចាស់សន្យាជាមួយយើងនៅក្នុង ភីលីព ៤:១៩ ថា " ព្រះរបស់ខ្ញុំនឹងបំពេញសេចក្តីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គដោយរួមក្នុងអង្គព្រះយេស៊ូគ្រីស្ត ។ " ព្រះជាម្ចាស់ក៏បានសន្យាជាមួយនឹងយើងផងដែរ នៅក្នុង យ៉ូហាន ១៦:១៣ ថា " កាលណាព្រះវិញ្ញាណនៃសេចក្តីពិតយាងមកដល់ ព្រះអង្គនឹងណែនាំអ្នករាល់គ្នាអោយស្គាល់សេចក្តីពិត...។ " ដោយសារព្រះវិញ្ញាណគឺជាគ្រូរបស់អ្នក នោះការអធិស្ឋាន និង ការស្តាប់ព្រះជាម្ចាស់គឺជាជំហានមួយដ៏សំខាន់បំផុតក្នុងការស្វែងរកផ្លូវរបស់ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការរបស់អ្នក ។

ស្វែងរកអោយឃើញនូវអ្វីព្រះគម្ពីរចែងអំពីការល្បួង និង តំរូវការអ្នកមាននៅក្នុងជីវិតរបស់អ្នក ។ នេះគឺជាសំនួរដើម្បីសួរខ្លួងឯងនៅពេលអ្នកសិក្សាអ្វីដែលព្រះគម្ពីរចែងអំពីការល្បួងណាមួយ ។

តើព្រះជាម្ចាស់មានព្រះបន្ទូលថាអ្វីដែលបណ្តាលអោយមានការល្បួង?

យ៉ាកុប ១:១៤-១៥ ១ យ៉ូហាន ២:១៥-១៧

តើព្រះជាម្ចាស់មានព្រះបន្ទូលថាអ្វីជាផលវិបាកកើតចេញពីការធ្វើតាមការល្បួង?

យ៉ាកុប ១:១៥ សុភាសិត ៥:៧-១៤ សុភាសិត ៦:២៥-៣១

រ៉ូម ៦:២៣ ១ យ៉ូហាន ២:១៧

តើខ្ញុំអាចយកឈ្នះលើការល្បួងដោយរបៀបណា?

តើសេចក្តីសន្យាអ្វីរបស់ព្រះជាម្ចាស់ដែលខ្ញុំអាចប្រាប់គេបាន?

តើព្រះជាម្ចាស់ចង់អោយខ្ញុំបំពេញតំរូវការដែលខ្ញុំមាននេះដោយរបៀបណា?

តើខ្ញុំអាចប្រើការល្បួងនេះអោយចូលទៅជិតព្រះជាម្ចាស់បានដោយរបៀបណា?

វាមានប្រយោជន៍ណាស់ដើម្បីពិភាក្សាបញ្ហារបស់អ្នកជាមួយគ្រីស្តបរិស័ទដទៃទៀត ដោយសារតែគ្រីស្តបរិស័ទភាគច្រើនប្រឈមមុខទៅនឹងការល្បួងដូចគ្នា ។ តើពួកគេបានរៀនយកឈ្នះលើការល្បួងនេះដោយរបៀបណា? តើអត្ថបទព្រះគម្ពីរអ្វីដែលបានជួយពួកគេច្រើនបំផុត?

នៅពេលអ្នករកឃើញខគម្ពីរនៅក្នុងព្រះគម្ពីរដែលជួយអ្នក អោយចងចាំខគម្ពីរទាំនេះ ។ លើកយកខគម្ពីរទាំងនេះមកដាក់ខ្លួនអ្នកអោយពេញមួយថ្ងៃ ជាពិសេសនៅពេលដែលអ្នកតែងតែប្រឈមមុខការល្បួងនោះ ។

## ៨. ធ្វើការប្តេជ្ញាចិត្តដើម្បីបំពេញតំរូវការរបស់អ្នកតាមផ្លូវរបស់ព្រះអង្គ

សាតាំងនឹងមិនបញ្ឈប់ល្បួងអ្នកដោយគ្រាន់តែអ្នកស្គាល់ផ្លូវរបស់ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការរបស់អ្នកនោះទេ ។ វានឹងបន្តល្បួងអ្នកអោយធ្វើទៅតាមវិធីរបស់វា-វិធីស្រួល ។ ប្រសិនបើអ្នកមានជ័យជំនះក្នុងការប្រឆាំងការល្បួងអារក្សសាតាំង នោះអ្នកនឹងឈរយ៉ាងរឹងមាំនៅលើការប្តេជ្ញាចិត្តរបស់អ្នកដើម្បីចូលទៅជិតព្រះជាម្ចាស់រាល់ថ្ងៃ ។ ប្រសិនបើអ្នកធ្វើការសំរេចចិត្តដើរតាមផ្លូវរបស់ព្រះជាម្ចាស់គ្រប់ពេល នោះអ្នកនឹងមិនចាំបាច់គិតអំពីការល្បួងនីមួយៗនោះទេៈ " តើផ្លូវមួយណាខ្ញុំគួរទៅ-ផ្លូវរបស់ព្រះជាម្ចាស់ ឬក៏ ផ្លូវសាតាំង ? " ។

ជួនកាលសាតាំងនឹងល្បួងអ្នកអោយបំពេញតំរូវការដែលមិនសូវសំខាន់ដូចតំរូវការផ្សេងទៀតដែលអ្នកមាន ។ នៅពេលដែលព្រះយេស៊ូគង់នៅវាលរហោស្ថាន និង អធិស្ឋានតមអាហារ ទ្រង់ឃ្លានណាស់បន្ទាប់ពីចំណាយពេលវេលា ៤០ ថ្ងៃនៅទីនោះ ។ សាតាំងបានមកល្បួងព្រះយេស៊ូអោយធ្វើដុំថ្មទៅជានំប៉័ង ។ ទ្រង់ឃ្លាន និង រូបកាយរបស់ទ្រង់ត្រូវការម្ហូបអាហារ ។ នេះគឺជាតំរូវការពិតប្រាកដ ។ ប៉ុន្តែព្រះយេស៊ូបានបដិសេធនឹធ្វើតាមដំបូន្មានរបស់អារក្សសាតាំង ដោយសារតែទ្រង់បានដឹងថាព្រះជាម្ចាស់ចង់ឱ្យទ្រង់បំពេញតំរូវការដទៃទៀតជាមុនសិន ។ ( សូមមើល ម៉ាថាយ ជំពូក ទី ៤ )

មិនយូរប៉ុន្មាន ព្រះយេស៊ូបានអធិប្បាយព្រះបន្ទូលនៅក្នុង ម៉ាថាយ ៥-៧ ដែលគេហៅថា ការអធិស្ឋាននៅលើភ្នំ ។ នៅចំនុចមួយ ទ្រង់បានមានព្រះបន្ទូលអំពី អាទិភាពរបស់ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការរបស់យើង ។

**ម៉ាថាយ ៦:៣១-៣៣ ហេតុនេះកុំខ្វល់ខ្វាយដោយពោលថា " យើងនឹងមានអ្វីបរិភោគ មានអ្វីស្លៀកពាក់? " នោះឡើយ ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះទេ ដែលខំស្វះស្វែងរករបស់ទាំងនោះ ។ រីឯព្រះបិតាដែលគង់នៅស្ថានបរមសុខ ទ្រង់ជ្រាបនូវអ្វីដែលអ្នករាល់ត្រូវការ ។ ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និង សេចក្ដីសុចរិតរបស់ព្រះអង្គជាមុនសិនទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត ។**

យើងអាចជឿជាក់ថា វាគឺជាព្រះហឬទ័យរបស់ព្រះជាម្ចាស់ដើម្បីបំពេញនូវតំរូវការរបស់យើង ។ ប៉ុន្តែវាប្រហែលជាមិនត្រូវទៅនឹងពេលវេលារបស់ទ្រង់អោយយើងបំពេញតំរូវការណាមួយនោះ ។ ព្រះយេស៊ូទ្រង់ជ្រាបដឹងថានៅពេលដែលទ្រង់គង់នៅវាលរហោស្ថាន វាមិនមែនជាពេលរបស់ព្រះជាម្ចាស់សំរាប់ផ្ដល់ចំណីអាហារដល់ទ្រង់នោះទេ ទោះបីជាទ្រង់ឃ្លានក៏ដោយ ។ សាតាំងវាព្យាយាមអោយអ្នកចំណាយពេលវេលាទាំងអស់របស់អ្នកដើម្បីបំពេញតំរូវការណាដែលផ្ដល់ផលប្រយោជន៏អោយអ្នកប៉ុណ្ណោះ ។ តាមផ្លូវនេះ អ្នកនឹងមិនមានពេលវេលា ឬក៏ លុយកាក់ដើម្បីបំពេញតំរូវការអ្នកដទៃនៅជុំវិញអ្នកនោះទេ ។

សេចក្ដីសន្យារបស់ព្រះជាម្ចាស់ច្បាស់លាស់ណាស់-ព្រះអង្គនឹងផ្គត់ផ្គង់គ្រប់ទាំងតំរូវការរបស់អ្នក ។ ប៉ុន្តែជួនកាល វាពិបាកក្នុងការយល់ដឹងថា កិច្ចការមួយណាជាតំរូវការ ឬក៏ ចំណង់នោះ ។ សាតាំងនឹងធ្វើគ្រប់អ្វីៗទាំងអស់ឱ្យអ្នកជឿថាអ្នកត្រូវការអ្វីមួយ ដែលតាមពិតនោះ វាកំពុងតែធ្វើអោយអ្នកចាប់អារម្មណ៏ចំណង់មួយនៅក្នុងចំណង់ជាច្រើនរបស់អ្នក ។ សូមអោយយើងមើលពីរបៀបចំណង់របស់យើងជាប់ទាក់ទងនៅក្នុងការរៀបចំសំរាបក់ការល្បួង ។

**ព្រះជាម្ចាស់បានសន្យាផ្ដល់នូវគ្រប់ទាំងតំរូវការរបស់អ្នក ។**

## គ. សូមអោយព្រះជាម្ចាស់កំណត់នូវចំណង់ដ៏សមរម្យ

សាតាំងវាពូកែខាងសិល្បៈនៃការដើរខ្សែលើចំណង់របស់មនុស្ស នឹងល្បួងពួកគេឱ្យបំពេញចំណង់របស់ពួកគេអស់រយៈពេលជាយូរមកហើយ ។ ជនរងគ្រោះរបស់វាដំបូង គឺ អេវ៉ានៅក្នុងសួនអេដែន.. ។ វាធ្វើអោយនាងអេវ៉ាជឿថា នាងនឹងដូចព្រះជាម្ចាស់ ប្រសិនបើនាងញ៉ាំផ្លែឈើចេញពីដើមដែលព្រះជាម្ចាស់ហាមនាងញ៉ាំនោះ ។ អេវ៉ាមិនចាំបាច់ក្លាយដូចជាព្រះជាម្ចាស់នោះទេ ។ ប៉ុន្តែនាងបានសំរេចិត្តថា វាគឺជាការល្អដូចព្រះអង្គ ។ អេវ៉ាចង់ដឹងថា នាងនឹងមានលក្ខណៈយ៉ាងដូចម្ដេច ។ មិនយូរប៉ុន្មាន អាដាំបានចូលរួមជាមួយនឹងការញ៉ាំផ្លែនោះដែរ ។

នៅពេលដែលយើងបំពេញតំរូវការរបស់យើងតាមផ្លូវរបស់អារក្សសាតាំង

ផលវិបាកវាតែងតែមានការឈឺចាប់ ។ វានឹងអោយយើងឃ្លាតឆ្ងាយពីព្រះជាម្ចាស់ និង ការសប្បាយដែលយើងបានទទួលពីការបំពេញចំណង់នោះគឺមានរយៈពេលខ្លីណាស់ ។ តើគ្រប់ទាំងចំណង់របស់យើងខុសទាំងអស់? តើគ្រីស្ទបរិស័ទថ្មីត្រូវតែបង្កើតចំណង់ថ្មីទាំងអស់ឬយ៉ាងណា? តើព្រះជាម្ចាស់ចង់បំពេញចំណង់របស់យើងដែរឬទេ? តើចំណង់របស់យើងស៊ីគ្នាទៅនឹងការរៀបចំសំរាប់ការល្បួងឬទេ?

### ១. រកអោយឃើញនូវអ្វីដែលព្រះជាម្ចាស់សព្វព្រះន័យ

ព្រះជាម្ចាស់ចង់អោយអ្នកសប្បាយចិត្ត ។ ព្រះជាម្ចាស់ចង់អោយអ្នកមានសេចក្តីអំណរជាមួយនឹងជីវិត ។ ទ្រង់ចង់អោយជីវិតរបស់អ្នកពេញលេញ និង សំបូរសប្បាយ ។ ប្រសិនបើអ្នកសំរេចចិត្តដើរតាមព្រះគ្រីស្ទ នោះអ្នកចាំបាច់ត្រូវតែបង្កើតចំណង់ដូចដែលទ្រង់មាន ។ សូមរកអោយឃើញនូវអ្វីដែលព្រះជាម្ចាស់ចូលចិត្ត និង រៀនចូលចិត្តនូវអ្វីដែលទ្រង់ចូលចិត្ត ។ ដូច្នេះ គាត់នឹងមិនរស់នៅសំរាប់ចំណង់អាក្រក់របស់អារក្សសាតាំងនោះទេ ប៉ុន្តែរស់នៅសំរាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ប្រសើរជាង ។

**រៀនចូលចិត្តនូវអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យ។**

**ទំនុកតម្កើង ១:១-២ មានសុភមង្គលហើយ អ្នកដែលមិនដើរតាមដំបូន្មានរបស់មនុស្សពាល មិនឈរក្នុងមាគ៌ារបស់មនុស្សបាប ហើយក៏មិនអង្គុយរួមជាមួយពួកអ្នកចំអកឡកឡឺយ ផ្ទុយទៅវិញ គេចូលចិត្តនឹងវិន័យរបស់ព្រះអម្ចាស់ ព្រមទាំងសញ្ជឹងគិតអំពីវិន័យរបស់ព្រះអង្គទាំងយប់ទាំងថ្ងៃ ។**

ខគម្ពីរទី ២ នៃទំនុកតម្កើងនេះពិពណ៌នាពីជីវិតរស់នៅរបស់គ្រីស្ទបរិស័ទដែលចំណង់របស់គាត់ដូចគ្នាទៅនឹងព្រះជាម្ចាស់ ។ " ពួកគេចូលចិត្តធ្វើអ្វីៗដែលព្រះជាម្ចាស់ចង់អោយពួកគេធ្វើ ។ " តើគ្រីស្ទបរិស័ទថ្មីអាចដឹងដោយរបៀបណានូវអ្វីដែលព្រះជាម្ចាស់ចង់អោយពួកគេធ្វើ? ផ្នែកបន្ទាប់មកទៀតនៃខគម្ពីរនេះពន្យល់ពីរបៀប : " គេចូលចិត្តនឹងវិន័យរបស់ព្រះអម្ចាស់ ព្រមទាំងសញ្ជឹងគិតអំពីវិន័យរបស់ព្រះអង្គទាំងយប់ទាំងថ្ងៃ ។ " នៅពេលដែលអ្នកចំណាយពេលវេលានៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្នកនឹងរៀនអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ ។ អ្នកនឹងរៀនគិតដូចអ្វីដែលព្រះជាម្ចាស់គិត ។

ទំនុកតម្កើង ៣៧:៤-៥ ចូរស្វែងរកសុភមង្គលពីព្រះអម្ចាស់ នោះព្រះអង្គនឹងប្រោសប្រទាននូវអ្វីៗដែលអ្នកប្រាថ្នាចង់បាន ។ ចូរផ្ញើវាសនារបស់អ្នកទៅក្នុងព្រះហស្តរបស់ព្រះអង្គ ចូរផ្ញើជីវិតលើព្រះអង្គ នោះទ្រង់នឹងជួយអ្នក ។

ប្រសិនបើអ្នកស្វែងរកសុភមង្គលនៅក្នុងព្រះអម្ចាស់ នោះព្រះអង្គនឹងផ្តល់អោយ

អ្នកនូវអ្វីដែលអ្នកចង់បាន ។ ប៉ុន្តែប្រសិនបើអ្នកស្វែងរកសុភមង្គលតាមបែបលោកីយវិញ នោះព្រះជាម្ចាស់នឹងមិនបំពេញចំណង់ទាំងនោះ នោះទេ ។

### ២. បោះបង់ចោល ចំណង់អំពើបាបចាស់

មុនពេលដែលអ្នកក្លាយជាគ្រីស្តបរិស័ទ អ្នកប្រហែលជាមិនបានព្យាយាមរកឱ្យឃើញផ្លូវរបស់ព្រះជាម្ចាស់ក្នុងការបំពេញចំណង់របស់អ្នកនោះទេ ។ ការធ្វើតាមផ្លូវរបស់សាតាំង អ្នកនឹងត្រូវជាប់អន្ទាក់ដោយសារចំណង់ទាំងនោះ ។ ឧទាហរណ៍ យុវជនដែលសំរេចចិត្តពិសោធន៍ជាមួយនឹងថ្នាំញៀនអាចញៀននឹងថ្នាំញៀនពេលក្រោយ ។ ហើយក៏មានយុវជនជាច្រើនដែលចាប់ផ្តើមជក់បារីដោយសារតែពួកគេចង់អោយមិត្តភ័ក្តិរបស់ពួកគេ

២៦

ទទួលយកខ្លួន ក្រោយមកពួកគេយល់ដឹងថា វាបានក្លាយទៅជាទំលាប់ដែលពិបាកនឹងបំបាត់បាន ។

ប្រហែលជានៅក្នុងអតីតកាលថ្មីៗរបស់អ្នក អ្នកបានរៀនអរសប្បាយជាមួយនឹងសកម្មភាពណាមួយដែលអ្នកឥឡូវនេះយល់ដឹងថា វាគឺជាអំពើបាប ។ ព្រះជាម្ចាស់ប្រាប់យើងយ៉ាងច្បាស់អោយលះបង់ចោលចំណង់ជីវិតចាស់របស់យើង ។

**អេភេសូ ៤:២១-២៤ ប្រសិនបើបងប្អូនបានឮគេនិយាយអំពីព្រះយេស៊ូ ហើយប្រសិនបើបងប្អូនបានទទួលការអប់រំអំពីព្រះអង្គស្របតាមសេចក្តីពិតដែលមកពីព្រះអង្គមែន ។ បងប្អូនត្រូវតែលះបង់កិរិយាមាយាទដែលបងប្អូនធ្លាប់កាន់ពីដើម គឺត្រូវដោះជីវិតចាស់ដែលកំពុងតែវិនាសតាមការលោភលន់បញ្ឆោតចិត្តនេះចោលទៅ ។ ត្រូវប្រែគំនិតប្រាជ្ញា និង វិញ្ញាណអោយបានថ្មីឡើង ហើយត្រូវពាក់ជីវិតថ្មីដ៏សុចរិត និង វិសុទ្ធមកពីសេចក្តីពិត ជាជីវិតដែលព្រះជាម្ចាស់បានបង្កើត ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ ។**

**កូឡូស ៣:៥ ដូច្នេះ សូមបងប្អូនសម្លាប់អ្វីៗខាងលោកីយ៍ចោលទៅ គឺអំពើប្រាសចាកសីលធម៌ អំពើសៅហ្មង ចិត្តស្រើបស្រាល បំណងប្រាថ្នាអាក្រក់ និង ចិត្តលោភលន់ គឺយកទ្រព្យសម្បត្តិធ្វើជាព្រះ ។**

នៅក្នុង កណ្ឌគម្ពីរពីរនេះគឺជាបញ្ជីបង្ហាញពីចំណង់ និង ទំលាប់បាប ដែលយើងត្រូវតែលះបង់ចោលពីជីវិតរបស់យើង ។ សូមមើល អេភេសូ ៤:១៧-៣២និង កូឡូស ៣:៥-១៥ ។

វានឹងត្រូវចំណាយពេលវេលាខ្លះដើម្បីសម្លាប់ចោលចំណង់ចាស់ ។ ជាច្រើនដងគ្រីស្តបរិស័ទថ្មីត្រូវតែប្រយុទ្ធជាមួយនឹងចំណង់ទាំងនេះមុននឹងចំណង់នេះយកឈ្នះលើខ្លួនបាន ។ ការបកស្រាយរបស់គ្រីស្តបរិស័ទម្នាក់ថា " ជួនកាល ខ្ញុំឆ្ងល់ថា ខ្ញុំពិតជាគ្រីស្ត

បរិស័ទឬយ៉ាងណា ។ ខ្ញុំពិតជាចង់បំរើព្រះជាម្ចាស់ ។ ហេតុអ្វីបានជាចំណង់ចាស់ទាំងនេះនៅតែគួរអោយចាប់អារម្មណ៏ដដែល? ខ្ញុំបានប្រាប់ព្រះជាម្ចាស់ថា ខ្ញុំចង់បោះបង់ជីវិតរស់នៅចាស់របស់ខ្ញុំ ។ ហេតុអ្វីបានជាព្រះជាម្ចាស់មិនយកជីវិតរស់នៅចាស់ទាំងនេះចេញពីពីខ្ញុំ?

គន្លឹះមួយក្នុងការយកជ័យជំនះចំណង់ចាស់គឺត្រូវជំនួសពួកគេជាមួយនឹងចំណង់ថ្មី ។ គ្រីស្តបរិស័ទថ្មីខ្លះមានការលំបាកជាមួយនឹងចំណង់ចាស់ខ្លះៗ ដោយសារតែពួកគេគ្រាន់តែព្យាយាមបំបាត់ចោលចំណង់ចាស់ដោយមិនជំនួសវាជាមួយនឹងចំណង់ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ ។ ប្រសិនបើអ្នកព្យាយាមផ្លូវនេះ អ្នកបង្កើតអោយមានសុញ្ញកាសនៅខាងក្នុងដែលកិច្ចការនោះវាអោយអ្នកជាចំនុចស៊ីបមួយដ៏ងាយស្រួលសំរាប់ការល្បួងរបស់អារក្សសាតាំង ។

**គន្លឹះគឺត្រូវរៀបចំផែនការថាតើចំណង់មួយណានឹងជំនួសចំណង់ចាស់ ។**

ប៉ុន្តែអ្នកអាចមានគំរោងផែនការអ្វីដែលអ្នកនឹងធ្វើនៅពេលសាតាំងព្យាយាមអោយបំពេញចំណង់ចាស់មួយរបស់អ្នក ។ អ្នកអាចប្រើការល្បួងនីមួយៗនៅក្នុងកន្លែងនេះជា នាឡិការោរ ដើម្បីរំលឹកអ្នកអោយធ្វើការបង្កើតចំណង់ថ្មីដែលព្រះជាម្ចាស់ចង់ឱ្យអ្នកមាន ។ កិច្ចការប្រឆាំងនឹងអ្វីដែលសាតាំងកំពុងធ្វើ ។ នៅពេលដែលវាឃើញថា ការល្បួងរបស់វាគឺគ្រាន់តែជួយអ្នកអោយក្លាយជាគ្រីស្តបរិស័ទប្រសើរឡើងថែមទៀតនោះ វាប្រហែលជានឹងបោះបង់ការល្បួងនោះ ។

គន្លឹះដើម្បីធ្វើអោយកិច្ចការនេះដំណើរការបានគឺត្រូវរៀបចំផែនការថាតើចំណង់មួយណានឹងត្រូវផ្លាស់ប្តូរចំណង់ចាស់នោះ ។ សូមស្វែងរក អត្ថបទគម្ពីរដែលទាក់ទងទៅនឹងចំនុចនោះ និង ត្រូវចងចាំខគម្ពីរនោះ ។ លើកយក ខគម្ពីរនោះសំរាប់ខ្លួនអ្នកអោយបានពេញមួយថ្ងៃ ទោះបីជាមានសាតាំងល្បួងអ្នកឬក៏ មិនល្បួងអ្នកនៅក្នុងកន្លែងនោះក៏ដោយ ។

អ្នកអាចផ្លាស់ប្តូរចំណង់របស់អ្នកបាន ។ វាប្រហែលជាមិនងាយស្រួលនោះទេ ។ ប៉ុន្តែការប្តេជ្ញាចិត្តដ៏រឹងមាំក្នុងការដើរតាមព្រះគ្រីស្តគឺជាជំហានដំបូងដើម្បីយកជ័យជំនះលើកន្លែងនេះ ។

## ៣. ប្រើតំលៃខាងព្រះគម្ពីរដើម្បីផ្លាស់ប្តូរចំណង់របស់អ្នក

តើអ្វីដែលពិតជាសំខាន់ចំពោះអ្នកនៅក្នុងជីវិត? តើកិច្ចការអ្វីដែលអ្នកអោយតំលៃខ្ពស់បំផុត? តើអ្វីជាជំនឿរបស់អ្នក? ទាំងអស់គឺត្រូវទៅទន្ទឹមគ្នាដើម្បីបង្កើតតំលៃរបស់អ្នក ។ យើងទាំងអស់គ្នាមានតំលៃ : ខ្លះដូចព្រះគម្ពីរ, ខ្លះទៀតប្រហែលជាវប្បធម៌ ឬក៏ដូចលោកីយ៏ ។ គ្រីស្តបរិស័ទថ្មីចាំបាច់ត្រូវតែចំណាយពេលវេលាដើម្បីធ្វើការប៉ាន់ប្រមាណ

តំលៃរបស់ពួកគេ ។ វាសំខាន់ជាពិសេសប្រសិនបើអ្នកចង់បង្កើតជីវិតរស់នៅជាគ្រីស្តបរិស័ទដ៏រឹងមាំនោះ ។

យើងអាចប្រើតំលៃរបស់យើងដើម្បីវាស់នូវចំណង់របស់យើងបាន ។ មនុស្សខ្លះផ្តល់តំលៃយ៉ាងខ្ពស់ទៅលើការបរិភោគ ។ ពួកគេញ៉ាំច្រើនជាងធ្វើកិច្ចការផ្សេងទៀត ។ នៅពេលពួកគេអង្គុយញ៉ាំ ចំណង់របស់ពួកគេគ្រប់គ្រងទម្លាប់ញ៉ាំរបស់ពួកគេ ។ មនុស្សដែលផ្តល់តំលៃទាបទៅលើម្ហូបអាហារ និង តំលៃខ្ពស់ទៅលើកិច្ចការអ្វីផ្សេងទៀតនោះ ប្រហែលជាងាយស្រួលជាងក្នុងការគ្រប់គ្រងទំលាប់ញ៉ាំរបស់គាត់ ។

ពេលមួយព្រះយេស៊ូធ្វើដំណើរឆ្លងកាត់ស្រុកសាម៉ារីជាមួយនឹងសាវ័ករបស់ទ្រង់ ។ ពួកគេបានឈប់នៅខាងក្រៅក្រុង និង សាវ័កទាំង ១២ បានទៅទិញម្ហូបអាហារ ។ ពេលសាវ័កទៅទិញនោះប្រហែលជាពេលថ្ងៃត្រង់ និង មានស្ត្រីម្នាក់មកពីក្រុងមកយកទឹក ។

២៨ ព្រះយេស៊ូបានចាប់ផ្តើមសន្ទនាជាមួយនឹងស្ត្រីនោះ ដែលមិនយូរប៉ុន្មានព្រះអង្គបានបង្វែរការសន្ទនានោះអោយទៅជាការពិភាក្សាខាងព្រលឹងវិញ្ញាណវិញ ។ នៅពេលសាវ័កទ្រង់មកវិញ ពួកគេព្យាយាមអោយព្រះគ្រីស្តហូបម្ហូបខ្លះ ។ ប៉ុន្តែព្រះគ្រីស្តបានឆ្លើយតបថា " ខ្ញុំមានម្ហូបអាហាររបស់ខ្ញុំដែលអ្នកមិនយល់ទេ . . . " ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេ " គឺត្រូវស្តាប់បង្គាប់តាមព្រះទ័យរបស់អង្គដែលបានបញ្ជូនខ្ញុំមក និង បញ្ចប់កិច្ចការដែលព្រះអង្គអោយខ្ញុំធ្វើ ។ " ( យ៉ូហាន ៤:៣២, ៣៤)

ព្រះយេស៊ូអាចមិនចាប់អារម្មណ៍ចំពោះតំរូវការ និង ចំណង់ផ្ទាល់ខ្លួននៅពេលដែលទ្រង់ជាប់ទាក់ទងយ៉ាងពេញទំហឹងក្នុងការជួយអ្នកដទៃ ។ ប្រសិនបើអ្នកលំបាកក្នុងការយកជ័យជំនះចំណង់ចាស់ សូមពិនិត្យមើលថាតើអ្នកចំណាយពេលវេលាប៉ុន្មានក្នុងការជួយមនុស្សដទៃនោះ ។ ប្រសិនបើអ្នកមានទស្សនៈអាត្មានិយមមិនច្រើនទៅលើតំរូវការ និង ចំណង់ អ្នកប្រហែលជាស្រួលជាងមើលរំលងកិច្ចការខ្លះៗដែលក្តោបទៅលើអ្នកយ៉ាងខ្លាំងនោះ ។

សូមសួរខ្លួនឯង " តើវាសំខាន់ប៉ុណ្ណាតាមទស្សនៈរបស់ព្រះជាម្ចាស់ដែលខ្ញុំបំពេញចំណង់របស់ខ្ញុំនៅថ្ងៃនេះ ? " នៅពេលដែលយើងចាប់ផ្តើមមើលឃើញកិច្ចការពីទស្សនៈរបស់ព្រះជាម្ចាស់ វានឹងងាយស្រួលជាងក្នុងការយល់ដឹងថាតើចំណង់មួយណាគួរតែត្រូវបានបំពេញ និង មួយណាត្រូវតែបដិសេធចោលនោះ ។

ទោះជាអ្នកចំណាយពេលរៀបចំសំរាប់ការល្បួងប៉ុណ្ណាក៏ដោយ ក៏សាតាំងនឹងនៅតែល្បួងអ្នកអោយធ្វើអំពើបាបដែរ ។ ប៉ុន្តែ អ្នករៀបចំកាន់តែប្រសើរ នោះជ័យជំនះដែល

អ្នកមានចំពោះការល្បួងកាន់តែច្រើន ។

### ឃ. ការល្បួងខ្លះអាចការពារបាន

អ្វីដែលអ្នកគិតអំពី និងអ្វីដែលអ្នកបានចំណាយពេលវេលារបស់អ្នកធ្វើឱ្យមានឥទ្ធិពលយ៉ាងខ្លាំងនៅលើការល្បួងដែលអ្នកប្រឈមមុខ ។ នេះគឺជាចំនុចខ្លះៗដែលអ្នកអាចធ្វើដែលប្រហែលជាបញ្ឈប់សាតាំងពីការព្យាយាមល្បួងអ្នកអោយធ្វើអំពើបាបនៅក្នុងកន្លែងពិសេសណាមួយ ។

#### ១. ជៀសវាងកិច្ចការណា ដែលអ្នកដឹងថាជាអំពើបាប

**ត្រូវជៀសចេញអោយផុតពីអំពើអាក្រក់គ្រប់បែបយ៉ាង ។**

១ ថែស្សាឡូនិក ៥:២២ ចែងថា " ត្រូវជៀសចេញអោយផុតពីអំពើអាក្រក់គ្រប់បែបយ៉ាង ។ នេះគឺជាផ្លូវមួយដ៏សំខាន់បំផុតដើម្បីការពារការល្បួងជាច្រើន ។ អ្នកមិនចាំបាច់បង្ហាញភស្តុតាងដល់សាតាំងដែលអ្នកអាចទៅជិតកិច្ចការដែលពេញដោយអំពើបាបដោយគ្មានទទួលឥទ្ធិពលនោះទេ ។ ប្រសិនបើអ្នកមានបញ្ហាជាមួយនឹងការល្បួងស្រើបស្រាលនោះ កុំទៅជិតទស្សនាវដ្តីដែលមានរូបភាពមិនល្អនោះ ។ ប្រសិនបើអ្នកមានបញ្ហាជាមួយនឹងថ្នាំញៀន នោះត្រូវចេញអោយឆ្ងាយពីមនុស្សដែលមានថ្នាំញៀន ។

**ការមានទំនាក់ទំនងជាមួយគ្រីស្តបរិស័ទនឹងជួយអោយចូលជិតព្រះជាម្ចាស់**

មានការល្បួងជាច្រើនដែលអ្នកអាចការពារដោយនៅអោយឆ្ងាយពីបញ្ហា ។ ប៉ុន្តែអ្នកមិនអាចធ្វើកិច្ចការនេះជាមួយនឹងគ្រប់ការល្បួងនោះទេ ។ ប្រសិនបើអ្នកឡើងទំងន់ និង ល្បួងអោយញ៉ាំច្រើននោះ ដំណោះស្រាយគឺត្រូវនៅអោយឆ្ងាយពីម្ហូបអាហារអស់មួយជីវិតរបស់អ្នក លុះត្រាណាតែអ្នកចង់រស់នៅរយៈពេលខ្លីនោះ ។ មានការល្បួងខ្លះដែលយើងមិនអាចជៀសវាងបាន ។ យើងត្រូវតែរៀនពីរបៀបប្រឆាំងការល្បួងទាំងនោះគ្រប់ពេលដែលវាមក ។

#### ២. អប់រំជីវិតគំនិតរបស់អ្នក

សុភាសិត ២៣:៧ ចែងថា ចិត្តរបស់គេដូចជាសំដីរបស់គេ ។ ប្រសិនបើអ្នកបំពេញចិត្តគំនិតរបស់អ្នកជាមួយនឹងគំនិតបាប នោះសាតាំងអាចបង្វែរកិច្ចការទាំងនេះអោយទៅជាការល្បួងអោយធ្វើអំពើបាប ។ ប្រសិនបើអ្នកបំពេញចិត្តគំនិតរបស់អ្នកជាមួយកម្មវិធីទូរទស្សន៍មិនមែនជាគ្រីស្តបរិស័ទ នោះវានឹងប៉ះពាល់ដល់វិធីដែលអ្នករស់នៅ ។

កូឡុស ៣:១ ណែនាំយើងអោយបង្កើតគំនិតរបស់យើងនៅលើកិច្ចការដែលទាក់ទងចំពោះព្រះជាម្ចាស់ និង រស់នៅសំរាប់ទ្រង់ដោយមិនគិតអំពីផ្លូវលោកិយ៍ដែលពេញទៅដោយអំពើបាបនោះ ។ នៅពេលដែលអ្នករកឃើញចិត្តគំនិតរបស់គាត់បែរទៅរកជីវិតរស់នៅចាស់ដែលពេញទៅដោយអំពើបាបវិញនោះអ្នកនឹងត្រូវតែបញ្ឈប់ និង បង្ខំខ្លួនអ្នក

អោយគិតអំពីកិច្ចការដទៃទៀត ។ ភីលីព ៤:៨ ផ្តល់នូវបញ្ជីទាំងមូលនៃកិច្ចការសំរាប់គ្រីស្ទបរិស័ទដើម្បីគិតអំពី ។

**៣. ស្តាប់បង្គាប់ព្រះជាម្ចាស់ភ្លាមនៅពេលទ្រង់មានព្រះបន្ទូលមកកាន់អ្នក**

នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលទៅកាន់អ្នកតាមរយៈមនសិការរបស់អ្នក ឬក៏ តាមវិធីណាផ្សេងទៀត អ្នកត្រូវតែស្តាប់បង្គាប់ទ្រង់អោយបានលឿន ។ ប្រសិនបើអ្នកមិនបានស្តាប់បង្គាប់ទ្រង់ អ្នកនឹងផ្តល់ឱកាសអោយសាតាំងល្បួងអ្នក និង ផ្តល់អោយវានៅខាងអ្នក ។ ប្រសិនបើអ្នកស្តាប់បង្គាប់ព្រះជាម្ចាស់យ៉ាងលឿន នោះសាតាំងនឹងមិនមានឱកាសធ្វើអោយអ្នកច្របូកច្របល់នោះទេ ។ ព្រះវិញ្ញាណបរិសុទ្ធតែងតែសង្ឃឹមនូវការឆ្លើយតបពីអ្នកនៅពេលដែលព្រះអង្គមានបន្ទូលមកកាន់អ្នក ។

## ៤. ចំណាយពេលជាមួយគ្រីស្ទបរិស័ទផ្សេងទៀត

មនុស្សដែលអ្នកចំណាយពេលជាមួយតែងតែមានឥទ្ធិពលនៅលើអ្នក ។ ប្រសិនបើអ្នកចំណាយពេលជាមួយនឹងគ្រីស្ទបរិស័ទ អ្នកនឹងមើលឃើញថាមានការ
៣០ ល្បួងតិចតួចមករកអ្នក ប្រសិនបើអ្នកបានចំណាយពេលវេលាជាមួយនឹងអ្នកមិនជឿ នោះអ្នកនឹងមានការល្បួងច្រើន ។ អ្នកអាចការពារការល្បួងជាច្រើនដោយផ្តាច់មិត្តភាពជាមួយនឹងមនុស្សដែលព្យាយាមអោយអ្នកចូលរួមនៅក្នុងសកម្មភាពបាបរបស់ពួកគេ ។

អ្នកចាំបាច់ត្រូវចូលរួមក្នុងសកម្មភាពក្រុមជំនុំមួយ និង ចូលរួមយ៉ាងទៀតទាត់នៅក្នុងសកម្មភាពរបស់ពួកគេ ។ ការមានទំនាក់ទំនងជាមួយគ្រីស្ទបរិស័ទគឺជាផ្លូវដ៏ល្អបំផុតដើម្បីចូលទៅជិតព្រះជាម្ចាស់ ។ ប៉ុន្តែការចំណាយពេលវេលាជាមួយគ្រីស្ទបរិស័ទនឹងមិនតែងតែបញ្ឈប់សាតាំងពីការល្បួងអ្នកនោះទេ ។ កុំមានការភ្ញាក់ផ្អើល ប្រសិនបើ ឬក៏ នៅពេលអ្នកនៅក្នុងក្រុមជំនុំ វាដាក់ការល្បួងនៅក្នុងចិត្តគំនិតរបស់អ្នក ។

## ៥. ត្រូវប្រឆាំងជាមួយនឹងសាតាំងជានិច្ច

**ការមានទំនាក់ទំនងជាមួយគ្រីស្ទបរិស័ទនឹងជួយអោយចូលជិតព្រះជាម្ចាស់**

ជាមួយនឹងមនុស្សជាច្រើន សាតាំងដឹងថា វានឹងមិនទទួលជោគជ័យក្នុងការល្បួងពួកគេជាម្តងឬក៏ ពីរដងនោះទេ ។ ប៉ុន្តែ វាដឹងថាប្រសិនបើនៅតែបន្តមកល្បួងពួកគេទៀតពួកគេនឹងធ្វើតាមវានៅចុងបញ្ចប់ ។ វិធីមួយក្នុងការការពារការល្បួងគឺត្រូវតែប្រយុទ្ធប្រឆាំងជានិច្ចជាមួយពួកវា ។ ប្រសិនបើអ្នកអាចបង្ហាញដោយជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកថា អ្នកអាចប្រឆាំងការល្បួងពិសេសណាមួយរាល់ពេលដែលវាមក ប្រហែលជា

សាតាំងនឹងបោះបង់ចោលនៅក្នុងកន្លែងនោះមួយរយៈ ។

## ៦. ធ្វើអោយប្រាកដថា ព្រះជាម្ចាស់គឺជាអ្នកដឹកនាំពិតប្រាកដនៃជីវិតអ្នក

សំរាប់គ្រីស្តបរិស័ទជាច្រើន វាងាយស្រួលណាស់អធិស្ឋាននៅក្នុងក្រុមជំនុំ និង ប្រាប់ព្រះជាម្ចាស់ថា ពួកគេចង់អោយព្រះអង្គក្លាយជាអ្នកគ្រប់គ្រងជីវិតរបស់ពួកគេ ។ ប៉ុន្តែនៅក្នុងកំឡុងពេលមួយសប្តាហ៍ ជួលកាល វាងាយស្រួលភ្លេចការអធិស្ឋាននោះ និង ធ្វើអ្វីផ្សេងពីនោះ ។ កាឡាទី ៥:១៦ ផ្តល់អោយយើងនូវដំបូន្មានពីរបៀបយើងអាចការពារការល្បួងខ្លះបាន ។

**កាឡាទី ៥:១៦ ខ្ញុំសូមជំរាបថា ចូររស់នៅអោយស្របតាមព្រះវិញ្ញាណនោះបងប្អូននឹងមិនបំពេញតាមបំណងចិត្តលោភលន់របស់លោកីយ៍ទៀតឡើយ ។**

ការល្បួងអោយធ្វើអំពើបាបនឹងបន្តប្រឈមមុខសំរាប់គ្រប់គ្រីស្តបរិស័ទទាំងអស់ ប៉ុន្តែជាមួយនឹងជំនួយរបស់ព្រះជាម្ចាស់ យើងអាចទទួលជោគជ័យលើការល្បួងនោះ ។ ព្រះជាម្ចាស់បានសន្យាផ្តល់អោយយើងនូវកំលាំង និង ប្រាជ្ញា ។ យើងត្រូវតែរក្សានូវការសន្យារបស់ទ្រង់ ហើយចូលទៅជិតព្រះអង្គ ។

# ជំពូក ទី ៤
# ការស្វែងយល់ពីការ បរាជ័យ និង ដោះស្រាយវាតាមផ្លូវរបស់ព្រះជាម្ចាស់

វាមិនមែនជាព្រះទ័យរបស់ព្រះជាម្ចាស់ដែលអោយអ្នកធ្វើអំពើបាបនោះទេ ។ ព្រះអង្គបានបង្ហាត់បង្រៀនអ្នកអោយប្រឆាំង និង យកឈ្នះគ្រប់ការល្បួងដែលអ្នកនឹងប្រឈមមុខ ។ ប៉ុន្តែ អ្នកមិនតែងតែជ្រើសរើសផ្លូវរបស់ព្រះជាម្ចាស់ក្នុងការដោះស្រាយស្ថានភាព តែក៏ធ្វើតាមអារក្សសាតាំងវិញ ។ នេះគឺជាការពិត ប៉ុន្តែព្រះជាម្ចាស់ទ្រង់ព្រះនៃសេចក្តីមេត្តាករុណា និងអត់ទោសអោយអ្នក នៅពេលអ្នកសារភាពបរាជ័យរបស់អ្នកចំពោះព្រះជាម្ចាស់ ។

អ្នកបោកប្រាសដ៏ធំបំផុតគឺជាសាតាំង ។ ជួនកាលវាធ្វើអោយការល្បួងមើលទៅគួរអោយចាប់អារម្មណ៍ណាស់ ការនោះវាពិបាកប្រឆាំងណាស់ ។ តែទោះជាយ៉ាងណាក៏ដោយ សូមចាំទុកអោយបានច្បាស់ និង យល់ដឹងពីផលវិបាកនៃការធ្វើបាបវាអាចជួយអ្នកមិនអោយធ្វើអំពើបាបនោះទៀត ។

## ក. តើមានអ្វីកើតឡើងនៅពេលអ្នកធ្វើតាមការល្បួង?

សូមចំណាយពេលវេលាមួយនាទី និង គិតអំពីពេលវេលានៅពេលដែលអ្នកបានធ្វើតាមការល្បួងរបស់អារក្សសាតាំង ។ តើអ្វីបានកើតឡើងបន្ទាប់មក? តើផលវិបាកជាអ្វីខ្លះដែលអ្នកបានសង្ឃឹមទុក? ឥឡូវនេះ យើងនឹងមើលកិច្ចការផ្សេងគ្នាខ្លះៗដែលកើតឡើងនៅពេលអ្នកធ្វើតាមការល្បួង ។ ខណៈដែលមិនមានផលវិបាកណាមួយនៃផលវិបាកទាំងនេះនឹងមានគ្រប់ពេលដែលអ្នកបរាជ័យក្នុងការឆ្លើយតបផ្លូវរបស់ព្រះជាម្ចាស់ អ្នកអាចរកឃើញថាវាមានប្រយោជន៍ក្នុងការគិតអំពីផលវិបាកទាំងនេះនៅពេលអ្នកជួបប្រទះអោយធ្វើអំពើបាបនោះ ។ វាអាចជួយអ្នកអោយជឿ និង ធ្វើតាមផ្លូវរបស់ព្រះជាម្ចាស់ក្នុងការតំរូវការ និង ចំណង់របស់អ្នក ។

### ១. អ្នកប្រព្រឹត្តអំពើបាប

រាល់ពេលដែលអ្នកធ្វើតាមការល្បួងរបស់អារក្សសាតាំង អ្នកធ្វើខុសនឹងច្បាប់របស់ព្រះជាម្ចាស់ ។ លោកយ៉ាកុបពិពណ៌នាថា ផលវិបាកនៃការស្តាប់គំនិតដំបូង ។

**យ៉ាកុប ១ : ១៤-១៦ ម្នាក់ៗជួបនឹងការល្បួង មកតែពីចិត្តលោភលន់របស់ខ្លួនឯង ផ្ទាល់ទាក់ទាញ និង លួងលោមបញ្ឆោតប៉ុណ្ណោះ ។ ចិត្តលោភលន់រមែងតែងតែបង្កើត អំពើបាប លុះដល់អំពើបាបចំរើនដល់កំរិត ហើយក៏បណ្តាលអោយស្លាប់ ។ បងប្អូនជាទី ស្រលាញ់អើយ សូមកុំយល់ច្រឡំឡើយ ។**

សាតាំងនឹងព្យាយាមធ្វើអោយអ្នកភ្លេចក្នុងការធ្វើតាមផ្លូវរបស់វាដែលនាំអោយធ្វើអំពើបាប ។ ប៉ុន្តែ ដូចនៅ ខ ទី ១៦ ចែងថា កុំអោយសាតាំងបោកប្រាស់អ្នក ។

ប្រសិនបើអ្នកធ្វើអំពើបាប សូមសារភាពអំពើបាបរបស់អ្នកដល់ព្រះជាម្ចាស់ និង ស្វែងរកការអត់ទោសរបស់ព្រះអង្គ ។

## ២. អ្នកធ្វើអោយខ្លួនឯង និង អ្នកដទៃទៀតឈឺចាប់

សាតាំងនឹងព្យាយាមអោយអ្នកជឿថា គ្មានអ្វីអាក្រក់នឹងកើតឡើង ប្រសិនបើអ្នកធ្វើតាមការល្បួងរបស់វា ។ កុំជឿអារក្សសាតាំង ។ អំពើបាបតែងតែមានផលរបស់វា " ដ្បិតលទ្ធផលនៃអំពើបាបគឺជាសេចក្តីស្លាប់ រីឯព្រះអំណោយទានរបស់ព្រះជាម្ចាស់វិញ គឺជីវិតអស់កល្បជានិច្ចរួមជាមួយព្រះគ្រីស្តយេស៊ូជាព្រះអម្ចាស់នៃយើង ។(រ៉ូម ៦:២៣)

ការធ្វើអំពើបាបជះឥទ្ធិពលទៅលើអ្នក ប៉ុន្តែវាក៏ជះឥទ្ធិពលទៅលើអ្នកដទៃទៀតផងដែរ ជួនកាលវាខ្លាំងក្លាជាងអ្នកគិតទៅទៀត ។ អ្នកប្រហែលមិនទាន់ឃើញវាភ្លាមៗនោះទេ ប៉ុន្តែពេលវេលានឹងបង្ហាញពីការខូចខាតដែលបណ្តាលមកពីការធ្វើអំពើបាប ។

នៅក្នុងសញ្ញាចាស់ អំពើបាបរបស់ព្រះបាទដាវីឌជាមួយនឹងបាតសេបាមានផលវិបាកយ៉ាងខ្លាំងក្លា ។ គាត់បានប្រព្រឹត្តអំពើផិតក្បត់ និង បន្ទាប់មកសម្លាប់ប្តីរបស់បាតសេបាដើម្បីគ្របបាំងអំពើបាបរបស់គាត់ ។ ក្រោយមក ពេលដែលព្យាការីបានប្រាប់ពីអំពើបាបរបស់គាត់ ព្រះជាម្ចាស់បានដាក់ទោសគាត់ដោយយកជីវិតកូនដែលកើតចេញពីអំពើបាបរបស់គាត់ ។ ការដាក់ទោសរបស់ព្រះជាម្ចាស់ក៏ជះឥទ្ធិពលផងដែរទៅលើអនាគតកូនចៅរបស់ព្រះបាទដាវីឌ ។ សូមមើល ២ សាម៉ូអែល ១២:១០-១២ សំរាប់យល់ដឹងបន្ថែមទៀត ។ ពិតណាស់ព្រះបាទដាវីឌមិនគិតអំពីផលវិបាកដ៏ឈឺចាប់ទាំងអស់នេះទេ នៅពេលដែលសាតាំងល្បួងគាត់អោយធ្វើអំពើបាបជាមួយនឹងបាតសេបានោះ ។

**៣. អ្នកនឹងបំពេញតំរូវការបណ្តោះអាសន្នប៉ុណ្ណោះមិនមែនជាអចិន្ត្រៃន៍ទេ**

ដំណោះស្រាយដ៏លឿនរបស់អារក្សសាតាំងគឺមិនមែនជាដំណោះស្រាយជាអចិន្ត្រៃចំពោះតំរូវការនៅក្នុងជីវិតរបស់អ្នកនោះទេ ។ ផ្លូវតែមួយគត់ដើម្បីរកអោយឃើញនៅក្នុងការស្កប់ចិត្តនៅក្នុងជីវិតគឺត្រូវបំពេញតំរូវការនោះទៅតាមផ្លូវរបស់ព្រះជាម្ចាស់ ។ សាតាំង

តែងតែព្យាយាមអោយអ្នកគិតតែពីផលប្រយោជន៍ភ្លាមៗក្នុងការធ្វើតាមផ្លូវរបស់វាតែប៉ុណ្ណោះ វាមិនចង់ឱ្យអ្នកគិតពីថាតើមានរយៈពេលប៉ុន្មានចំពោះដំណោះស្រាយនោះទេ ។

## ៤. ការធ្វើតាមផ្លូវរបស់អារក្សសាតាំងបង្កើននូវតំរូវការ និង កំលាំងចំណង់

បន្ទាប់ពីអ្នកបានភ្លក់ការសប្បាយមួយភ្លែត, ការពេញចិត្តចំពោះភាពអាត្មានិយម អ្នកប្រហែលជាមានចំណង់កាន់តែខ្លាំងឡើងថែមទៀតដើម្បីបន្តនូវការសប្បាយនោះ ។ សុភមង្គលដែលអ្នកមានតែមួយរយៈពេលខ្លីប៉ុណ្ណោះ ។ ពេលការសប្បាយបណ្តោះអាសន្នចេញបាត់ទៅ តំរូវការ និង ចំណង់នឹងនៅតែនៅទីនោះដដែលប៉ុន្តែថែមទាំងមានកំឡាំងខ្លាំងឡើងថែមទៀត ។

## ៥. ការធ្វើតាមអារក្សសាតាំងម្តងនឹងនាំអោយអ្នកនៅកាន់ចំណង់ដ៏ធំជាងនេះទៀត

អំពើបាបតែងតែមានផល រឺ ផ្លែរបស់វា ។

អ្នកមានតំរូវការ អ្នកចង់បំពេញតំរូវការនោះ ។ គ្មានអ្វីដែលកើតឡើងពីការបញ្ចប់របស់ព្រះជាម្ចាស់នោះទេ ។ អ្នកក្តៅក្រហាយ ។ សាតាំងល្បួងអ្នក ដូច្នេះអ្នកធ្វើតាមការក្តៅក្រហាយនោះ និង ព្យាយាមបំពេញតំរូវការតាមផ្លូវរបស់អារក្សសាតាំង ។ ប៉ុន្តែមិនបានប៉ុន្មានផង តំរូវការនោះត្រឡប់មកវិញ និង ការក្តៅក្រហាយផងដែរ ។ ប៉ុន្តែ តំរូវការនៅក្នុងជីវិតរបស់អ្នកនៅតែមិនទាន់បានបំពេញគ្រប់គ្រាន់នៅឡើយ ភាពក្តៅក្រហាយបន្តរីកចំរើនតទៅទៀត ។

## ៦. ការធ្វើតាមការល្បួងម្តងនឹងងាយស្រួលឱ្យមានការល្បួងម្តងទៀតកើតឡើងនៅពេលក្រោយ

" ពេលវេលាដំបូងតែងតែពិបាកបំផុត ។ ពេលក្រោយអ្នកនឹងមានអំណរកាន់តែច្រើន ។ " ប្រសិនបើអារក្សសាតាំងបានប្រើការប្រកែកនេះនៅក្នុងអ្នក វាគឺជាសញ្ញាយ៉ាងច្បាស់ថាវាកំពុងតែមានផែនការល្បួងអ្នកម្តងទៀតនៅក្នុងកន្លែងនេះ ។

ប្រសិនបើវាបានទទួលជោគជ័យពីរឬក៏ បីដង វានឹងព្យាយាមអោយអ្នកបំភ្លេចអំពីការក្លាយជាគ្រីស្តបរិស័ទ ។ " មើល៍ វាពិបាកណាស់សំរាប់អោយអ្នកក្លាយជាគ្រីស្តបរិស័ទ។ មើលខ្លួនឯងចុះ នុ៎ះជាពេលទី ៣ ដែលអ្នកបានធ្វើអំពើបាបនៅក្នុងសប្តាហ៍ " វានឹងធ្វើអ្វីៗទាំងអស់ដែលវាអាចធ្វើបានដើម្បីអោយអ្នកបាត់បង់សេចក្តីសង្ឃឹម ។ នៅពេលដែលសេចក្តីសង្ឃឹមបាត់បង់ទៅហើយ វាងាយស្រួលណាស់បោះបង់ចោល និង មិនព្យាយាមប្រឆាំងការល្បួងនៅពេលដែលវាមកវិញម្តងទៀត ។

## ៧. ការធ្វើតាមការល្បួងមួយនឹងនាំអ្នកអោយមានការល្បួងកាន់តែច្រើន ហើយធំទៀត

ជាច្រើនដងអារក្សសាតាំងនឹងប្រើការប្រកែកគ្នាៈ " នេះគឺជារឿងកំប៉ិចកំប៉ុកទេ ធ្វើវាទៅ វាមិនធ្វើអោយនរណាម្នាក់ឈឺចាប់នោះទេ ។ " ប្រសិនបើអ្នកធ្វើកិច្ចការអ្វីមួយដោយគិតថាកំប៉ិចកំប៉ុកវាមិនអីទេនោះ ពេលក្រោយវានឹងនាំការល្បួងធំជាងនេះ ។ សាតាំងក៏មានគំរោងផែនការដ៏ល្អផងដែរដើម្បីជួយអ្នកអោយគ្របបាំងអំពើបាបពិសេសណាមួយដែលអ្នកបានធ្វើ ។ ប៉ុន្តែ ផែនការគ្របបាំងរបស់អារក្សសាតាំងនេះតែងតែអោយអ្នកប្រព្រឹត្តអំពើបាបដទៃទៀតហើយផលវិបាកកាន់តែអាក្រក់ជាងនេះទៅទៀត ។

សាតាំងនឹងព្យាយាមធ្វើឱ្យអ្នកបាត់បង់សេចក្តីសង្ឃឹម។ វាគឺជាអ្នកបោកប្រាស់ដ៏អស្ចារ្យ!

រឿងដ៏អន្តរាយនៃអំពើបាបរបស់ព្រះបាទដាវីដ និង បាតសេបាគឺជាឧទាហរណ៍យ៉ាងច្បាស់នៃបញ្ហានេះ ( ២ សាម៉ូអែល ១១ និង ១២ ) អំពើបាបដំបូងរបស់ព្រះបាទដាវីឌគឺជាតណ្ហាចង់រួមភេទនៅក្នុងចិត្តគំនិតរបស់គាត់ ។ បន្ទាប់មកគាត់បានហៅ នាងបាតសេបាអោយចូលមកក្នុងវាំងរបស់គាត់ ។ គាត់បានប្រព្រឹត្តអំពើផិតក្បិត និង ធ្វើឱ្យនាងមានផ្ទៃពោះ ។ នៅពេលដែលព្រះបាទដាវីឌយល់ដឹងពីបញ្ហានេះ គាត់មានបំណង់គ្របបាំងអំពើបាបរបស់គាត់ដោយហៅប្តីរបស់បាតសេបាពីសង្គ្រាមអោយមកផ្ទះ ។ នៅពេលដែលផែនការគ្របបាំងអំពើបាបរបស់ព្រះបាទដាវីឌមិនបានទទួលជោគជ័យ គាត់បានរៀបចំសំរាប់អ៊ូរី ។ ផែនការសំលាប់នោះបានសំរេច-រហូតទាល់តែព្យាការី ណាថានមកនិងបង្ហាញអោយព្រះបាទដាវីឌដឹងពីអំពើបាបរបស់គាត់ ។ អំពើបាបមួយនាំអោយមានអំពើបាបមួយទៀត រហូតទាល់តែគាត់មិនអាចគេចរួច អត់មានផ្លូវគេចបានទេ ។

## ៨. បរាជ័យរបស់អ្នកអាចធ្វើអោយមានការងាយស្រួលសំរាប់អ្នកដទៃធ្វើតាមការល្បួងដូចគ្នា

វុធបានក្លាយជាគ្រីស្តបរិស័ទអស់រយៈពេលបីសប្តាហ៏ហើយឥឡូវនេះ ។ គាត់កំពុងតែជួបប្រទះការលំបាកក្នុងការបញ្ឈប់ទំលាប់ជក់បារី ។ ច្បាប់នៅក្នុងមជ្ឈមណ្ឌលនឹងជួយគាត់ខ្លះ ពីព្រោះនៅក្នុងមជ្ឈមណ្ឌលមិនអនុញ្ញាត្តអោយជក់បារីនោះទេ ។ ប៉ុន្តែយប់មិញគាត់ស្ទើរតែធ្វើតាមការល្បួងអោយជក់បារីទៅហើយ ។ មានមនុស្សផ្សេងនៅក្នុងមជ្ឈមណ្ឌលបានរើសបារី និង ជក់វានៅជាន់ខាងក្រោម ។ ក្លិនបារីបានធ្វើអោយការល្បួងរបស់អារក្សសាតាំងកាន់តែពិបាកទ្រាំថែមទៀតសំរាប់វុធដោះស្រាយ ។

មនុស្សដទៃទៀតប្រហែលជាគ្មានបំណងធ្វើអោយវុធពិបាកទ្រាំនោះទេ ។ គាត់មិនបានអញ្ជើញវុធឱ្យមកជក់បារីជាមួយគាត់នោះទេ ។ គាត់បានគិតថា ការលួច

ទៅជក់បារីនៅក្នុងបន្ទប់ជាន់ក្រោមដោយខ្លួនគាត់ផ្ទាល់មិនបានប៉ះពាល់ដល់អ្នកដទៃទេ ។

នៅពេលដែលអ្នកធ្វើតាមការល្បួង អ្នកដទៃនឹងទទួលឥទ្ធិពលផងដែរដោយអំពើបាបរបស់អ្នក ។ យើងទាំងអស់គ្នាមានការទទួលខុសត្រូវរស់នៅក្នុងជីវិតដ៏បរិសុទ្ធ ។ ព្រះយេស៊ូបានប្រើពាក្យខ្លាំងៗ និងប្រមានចំពោះមនុស្សដែលប្រើពាក្យសំដី និងសកម្មភាពរបស់គាត់ឱ្យអ្នកដទៃធ្លាក់ក្នុងអំពើបាប ។

**លូកា ១៧:១-៣ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកសាវ័កថា : " មានមូលហេតុជាច្រើន ដែលតែងតែបណ្ដាលអោយមនុស្សប្រព្រឹត្តអំពើបាប ។ ប៉ុន្តែ អ្នកណានាំគេអោយប្រព្រឹត្តអំពើបាប អ្នកនោះត្រូវវេទនាហើយ ។ ចំពោះអ្នកនោះ ប្រសិនបើគេយកត្បាល់ថ្មយ៉ាងធំមកចងក ទម្លាក់ទៅក្នុងសមុទ្រ ប្រសើរជាងទុកអោយគាត់នៅរស់ ហើយមនុស្សតូចតាចណា ម្នាក់ប្រព្រឹត្តអំពើបាប ។ ដូច្នេះអ្នករាល់គ្នាត្រូវប្រយ័ត្នខ្លួន! ប្រសិនបើបងប្អូនណាធ្វើខុសចំពោះអ្នក ចូរស្ដីប្រដៅគាត់ផង តែបើគាត់កែប្រែចិត្តគំនិត ចូរអត់ទោសអោយគាត់ទៅ ។**

មនុស្សទី ១ ដែលធ្វើតាមការល្បួងរបស់អារក្សសាតាំងអោយធ្វើអំពើបាបគឺ អេវ៉ា នៅក្នុងសួនអេដែន ។ ពេលគាត់បានធ្វើអំពើបាបនោះ គាត់បានទៅអោយអដាំចូលរួមជាមួយគាត់ហូបផ្លែឈើថែមទៀតផង ។ នៅពេលដែលអ្នកដទៃឃើញអ្នកធ្វើអំពើបាប ពួកគេនឹងគិតថា វាមិនអីទេសំរាប់អោយពួកគេធ្វើដូចគ្នានេះ ។

### ៩. ការធ្វើតាមការល្បួងនាំឱ្យគិតអ្វីដែលត្រូវនិងអ្វីដែលខុស

នៅពេលដែលអ្នកធ្វើតាមការល្បួងអោយធ្វើអំពើបាប អារក្សសាតាំងបានរៀបចំខ្លួនរួចជាស្រេច និង សុខចិត្តជួយអ្នកឱ្យគិតថាសកម្មភាពរបស់អ្នកត្រឹមត្រូវ ។ វានឹងផ្ដល់អោយអ្នកនូវការដោះសារជាច្រើនដើម្បីពន្យល់ពីមូលហេតុថាសកម្មភាពរបស់អ្នកពិតជាត្រឹមត្រូវ ។ វានឹងបង្ហាញអ្នកថា ស្ថានភាពនេះគឺជាករណីពិសេសចំពោះវិន័យរបស់ព្រះជាម្ចាស់ ។ សាតាំងនឹងបង្វែរសេចក្ដីពិតហើយ ព្យាយាមអោយអ្នកទទួលគំនិតដែលអ្នកបានធ្វើគឺពិតជាមិនមែនអំពើបាបនោះទេ ។ វានឹងព្យាយាមធ្វើអ្វីៗទាំងអស់ដើម្បីនាំអ្នកអោយញៀនចំពោះអំពើបាប ។

### ១០. អ្នកប្រហែលជាមានអារម្មណ៍ថាមានកំហុស

ព្រះជាម្ចាស់អោយយើងដឹងពេលយើងធ្វើអំពើបាប ។ ប៉ុន្តែ ជួនកាលយើងមិនបានឮព្រះជាម្ចាស់មានព្រះបន្ទូលនោះទេ ដោយសារតែយើងធ្វើតាមផ្លូវរបស់យើងដោយជ្រើសរើសមិនស្ដាប់ទ្រង់ ។ ប្រសិនបើអ្នកធ្វើតាមការល្បួង ព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើឱ្យ

អ្នកយល់ដឹងពីអំពើបាបរបស់អ្នក ។ ជាច្រើនដង អារម្មណ៍មានកំហុសនេះនឹងមកភ្លាមៗ បន្ទាប់ពីអ្នកបានបំពេញតំរូវការរបស់អ្នកតាមផ្លូវរបស់អារក្សសាតាំងនោះ ។ អ្នកនឹងមាន អារម្មណ៍ថាធូរស្បើយពីភាពតានតឹង និង ការរសាយចិត្តដែលតំរូវការនោះបាននឹងកំពុងតែបង្កើតឡើង ។ ឥឡូវនេះចិត្តគំនិតរបស់អ្នកបានសំរាក អ្នកអាចវាយតំលៃស្ថានភាពភាពរបស់អ្នក និង មើលឃើញអ្វីដែលបានកើតឡើងពិតប្រាកដ ។ ប្រសិនបើអ្នកឆាប់ដឹងខាងអារម្មណ៍ ព្រះជាម្ចាស់នឹងធ្វើអោយកាន់តែច្បាស់ថែមទៀត តាមរយៈការមានអារម្មណ៍ថាខុស ឬថាអ្នកខុសនោះ ។

ប៉ុន្តែសូមកុំធ្លាក់នៅក្នុងការប្រើអារម្មណ៍របស់អ្នកជាផ្លូវមួយដើម្បីបង្ហាញថា កិច្ចការមួយខុស ឬត្រូវនោះ ។ អ្នកខ្លះនិយាយថា " ប្រសិនបើ ខ្ញុំ គ្មានអារម្មណ៍ថាមានកំហុសចំពោះកិច្ចការនេះទេ នោះខ្ញុំនឹងទៅធ្វើកិច្ចការនោះ ។ " ប្រហែលជាគាត់បានធ្វើកិច្ចការនេះជាញឹកញាប់មកហើយ មនសិការរបស់គាត់មិនអាចបញ្ជូនសារតទៅទៀតបានទេ ។ ប៉ុន្តែវិន័យរបស់ព្រះជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងព្រះគម្ពីរ ។ របៀបដែលអ្នកមានអារម្មណ៍ចំពោះវិន័យរបស់ទ្រង់មិនធ្វើអោយពួកគេត្រូវ ឬក៏ ខុសនោះទេ ។ ប្រសិនបើព្រះជាម្ចាស់មានព្រះបន្ទូលថាកិច្ចការនោះគឺជាអំពើបាប យើងត្រូវតែយល់ព្រមជាមួយនឹងព្រះអង្គ មិនថាអារម្មណ៍របស់យើងយ៉ាងណានោះ ទេចំពោះកិច្ចការនោះ ។

ប្រសិនបើអ្នកធ្វើតាមការល្បួងមួយរបស់អារក្សសាតាំង ។ នោះវាសំខាន់ណាស់ដែលអ្នកសារភាពអំពើបាបរបស់អ្នក មិនថាអ្នកមានអារម្មណ៍ថាមានកំហុស ឬក៏ គ្មានកំហុសនោះទេ ។ ពេលដែលអ្នករៀនអោយកាន់តែឆាប់យល់ដឹងខាងវិញ្ញាណចំពោះព្រះជាម្ចាស់ អ្នកនឹងចាប់ផ្តើមមើលឃើញដូចជាទ្រង់ទតឃើញអញ្ចឹងដែរ ។

## ១១. ព្រះជាម្ចាស់នឹងមកស្វែងរកអ្នក

ប្រសិនបើអ្នកធ្វើអំពើបាប ព្រះជាម្ចាស់នឹងមិនបែរខ្នងដាក់អ្នកនោះទេ ។ ទ្រង់ស្រលាញ់អ្នក និងចង់ជួយអ្នកឱ្យឃើញការស្កប់ចិត្តយ៉ាងពិតប្រាកដនៅក្នុងជីវិត ។ ព្រះអង្គចង់ជួយអ្នកអោយមកផ្លូវត្រូវវិញ ។ ដោយសារតែទ្រង់ស្រលាញ់អ្នកយ៉ាងខ្លាំង ទើបទ្រង់អត់ទោសអោយអ្នក ។

នៅក្នុងសួនអេឌែន បន្ទាប់ពីអដាំ និង អេវ៉ាបានធ្វើអំពើបាប ព្រះជាម្ចាស់បានស្វែងរកពួកគេ ។ ព្រះជាម្ចាស់មិនរងចាំរហូតទាល់តែពួកគេមករកទ្រង់នោះទេ ។ ហើយទ្រង់ក៏ធ្វើយ៉ាងនោះដែរចំពោះយើង ។

យើងចាំបាច់ត្រូវតែប្រុងប្រយត្ន័មិនត្រូវរំលោបបំពានសេចក្តីស្រលាញ់ព្រះអង្គនោះទេ ។ ប្រសិនបើយើងពិតជាស្រលាញ់ព្រះជាម្ចាស់មែន យើងនឹងស្តាប់បង្គាប់ទ្រង់ជាមិនខាន ។ កុំធ្លាក់ទៅក្នុងអន្ទាក់នៃការធ្វើអំពើបាប និង និយាយទៅកាន់ខ្លួនឯងថា " អូ! នោះមិនអីទេ ព្រះជាម្ចាស់នឹងអត់ទោសឱ្យខ្ញុំនៅពេលខ្ញុំអធិស្ឋាននោះ ។ " រាល់ពេលដែលអ្នកធ្វើអំពើបាប អ្នកបានដើរនៅលើផ្លូវមួយដែលនាំអោយឃ្លាតឆ្ងាយពីព្រះជាម្ចាស់ ។ ការមានអាកប្បកិរិយាប្រភេទនេះ វានឹងធ្វើអោយមានការពិបាកក្នុងការស្តាប់នូវព្រះសូរសៀងប្រាប់ជាមុនរបស់ព្រះជាម្ចាស់ ។ ការស្តាប់ការល្បួងរបស់អារក្សសាតាំងវាមានភាពងាយស្រួលជាង ។

### ១២. អាកប្បកិរិយារបស់អ្នកចំពោះព្រះជាម្ចាស់ប្រហែលផ្លាស់ប្តូរ

មនុស្សខ្លះមានការភ័យខ្លាចព្រះជាម្ចាស់បន្ទាប់ពីពួកគេបានធ្វើអំពើបាប ។ ពួកគេជឿថាកិច្ចការនេះធ្វើអោយព្រះជាម្ចាស់ខឹង និង ដាក់ទោសពួកគេ ។ ដូច្នេះពួកគេព្យាយាមបិទបាំងព្រះជាម្ចាស់ ។ ប្រសិនបើអ្នកបានព្យាយាមធ្វើដូច្នេះ អ្នកដឹងថាវាមិនអាចទៅរួចនោះទេ ។ យើងមិនអាចបិទបាំងព្រះជាម្ចាស់បានទេ ។

ប្រសិនបើអ្នកពិតជាសោកស្តាយចំពោះអំពើបាបរបស់អ្នក អ្នកមិនចាំបាច់ភ័យខ្លាចព្រះជាម្ចាស់នោះទេ ទ្រង់មិនមែនជាព្រះពេញដោយកំហឹងនឹងរងចាំតែឱកាសបំផ្លាញអ្នកនោះទេ ។ ព្រះអង្គស្រលាញ់អ្នក និង ទ្រង់ពិបាកព្រះទ័យពេលអ្នកធ្វើអំពើបាប ។

## ខ. តើហេតុអ្វីបានជាអ្នកធ្វើតាមការល្បួង?

ពេលណាអ្នកធ្វើតាមការល្បួង អ្នកមិនអាចស្តីបន្ទោសអ្នកណាម្នាក់បានទេ ប៉ុន្តែបន្ទោសខ្លួនឯងសំរាប់អំពើបាបដែលអ្នកបានធ្វើ ។ វាមិនមែនជាកំហុសរបស់ព្រះជាម្ចាស់ ឬ កំហុសអារក្សសាតាំងនោះទេ ។ យើងម្នាក់ៗទទួលខុសត្រូវសំរាប់ការសំរេចចិត្តដែលយើងបានធ្វើ ។ ប៉ុន្តែសូមអោយយើងមើលនូវមូលហេតុខ្លះៗដែលអ្នកអាចធ្វើតាមការល្បួង ។

### ១. អ្នកមិនបានរៀបចំខ្លួនសំរាប់ការល្បួង

ព្រះជាម្ចាស់បានសន្យានៅក្នុង ១ កូរិនថូស ១០:១៣ ថាទ្រង់នឹងប្រទានមធ្យោបាយអោយចេញរួចរាល់ពេលយើងជួបប្រទះការល្បួង ។ អ្នកអាចប្រឆាំងនឹងការល្បួងបាន ប្រសិនបើអ្នកបានរៀបចំរួចរាល់-ការអធិស្ឋាន, ការសិក្សាព្រះគម្ពីរ, និង ការចូលទៅជិតព្រះជាម្ចាស់ ។

គ្រីស្ទបរិស័ទខ្លះខ្សោយពេកក្នុងការប្រឆាំងទៅនឹងការល្បួង ។ នោះមិនមែនជាកំហុសរបស់ព្រះជាម្ចាស់នោះទេ ។ ព្រះជាម្ចាស់បានបង្កើតអោយមានគ្រប់ទាំងកម្លាំងទាំងអស់ដែលអ្នកចាំបាច់ត្រូវមាន ។ ប៉ុន្តែប្រសិនបើអ្នកធ្វេសប្រហែសទំនាក់ទំនងរបស់អ្នកជាមួយនឹងទ្រង់ហើយ ខ្សោយខាងព្រលឹងវិញ្ញាណ វាងាយណាស់អោយអ្នកធ្វើអំពើបាបម្តងទៀត ។

ព្រះយេស៊ូបានប្រុងប្រៀបសំរាប់រាល់ការល្បួងដែលសាតាំងយកមកល្បួងព្រះអង្គ ។ ព្រះអង្គបានយល់ដឹងពីរបៀបវាយតំលៃ និង កំណត់តំរូវការ ឬក៏ ចំណង់មួយណាដែលសាតាំងកំពុងតែព្យាយាមអោយព្រះយេស៊ូបំពេញ ។ អ្នកក៏អាចមានជ័យជំនះផងដែរ ប្រសិនបើអ្នកចំណាយពេលវេលាប្រុងប្រៀបខ្លួនសំរាប់ការល្បួងនោះ ។

**២. អ្នកកំពុងតែព្យាយាមរស់នៅជីវិតគ្រីស្ទបរិស័ទដោយកំលាំងរបស់អ្នក**

អ្នកដទៃនឹងទទួលឥទ្ធិពលដោយសារអំពើបាបរបស់អ្នក ។

ប្រសិនបើអ្នកព្យាយាមរស់នៅជីវិតគ្រីស្ទបរិស័ទរបស់អ្នកដោយគ្មានជំនួយពីព្រះជាម្ចាស់ អ្នកអាចដឹងពិតប្រាកដថាការលំបាកនៅមិនឆ្ងាយទេ ។ វាមិនអាចទៅរួចក្នុងការប្រឆាំងគ្រប់ទាំងការល្បួងរបស់អារក្សសាតាំងនៅក្នុងកំឡាំងខ្លួនអ្នកផ្ទាល់នោះទេ ។

មនុស្សខ្លះមិនច្បាស់លាស់ ប្រសិនបើពួកគេចង់ក្លាយជាគ្រីស្ទបរិស័ទនោះទេ ។ ពួកគេកំពុងតែព្យាយាមដើរនៅលើរបង និងគិតថាទទួលការល្អបានទាំងសងខាង ។ បញ្ហាគឺនៅត្រង់ថា-អ្នកមិនអាចដើរនៅលើរបង និង ចូលទៅជិតព្រះជាម្ចាស់នៅពេលតែមួយនោះទេ ។ ប្រសិនបើអ្នកមិនប្រកាន់ខ្ជាប់ជីវិតជាគ្រីស្ទបរិស័ទអស់ពីចិត្តទេ អ្នកអាចក្លាយទៅជាជនរងគ្រោះយ៉ាងងាយស្រួលនៃការល្បួងរបស់អរក្សសាតាំង ។

ផ្លូវតែមួយគត់ដើម្បីទទួលជោគជ័យនៅលើការល្បួងរាល់ថ្ងៃគឺត្រូវប្តេជ្ញាចិត្តដើរតាមព្រះយេស៊ូ បើដូច្នោះទេគឺនឹងនាំអោយអ្នកមានបញ្ហាហើយ ។

**៣. អ្នកបោះបង់ចោលការព្យាយាមធ្វើតាមវិធីរបស់ព្រះជាម្ចាស់**

ព្រះជាម្ចាស់បានបង្កើតយើងម្នាក់ៗដោយអោយយើងមានតំរូវការ និង ចំណង់ ។ ព្រះអង្គសន្យាផ្គត់ផ្គង់គ្រប់ទាំងតំរូវការរបស់យើង ។ ប៉ុន្តែជួនកាល វាមិនងាយស្រួលយល់ដឹងនូវវិធីរបស់ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការ ឬក៏ចំណង់ទេ ។ ប្រហែលជាអ្នកមានបទពិសោធន៏នៃការមិនទទួលជោគជ័យក្នុងការបំពេញតំរូវការតាមផ្លូវរបស់ព្រះជាម្ចាស់ ។ ភាពក្តៅក្រហាយកើនឡើងនៅខាងក្នុង ដោយសារតែតំរូវការនោះមិនត្រូវបានបំពេញគឺនៅដដែល ។ អារក្សសាតាំងមកខ្សឹបថា " នេះគឺជាផ្លូវដ៏ងាយស្រួលបំផុតដើម្បីបំពេញតំរូវការរបស់អ្នក អ្នកឆ្អែតហើយក្នុងការព្យាយាមបំពេញតំរូវការនោះតាមផ្លូវរបស់ព្រះជាម្ចាស់ ។ វាប្រហែលជាមិនអាចទៅរួចទេសំរាប់អ្នកនោះ ។

សាតាំងព្យាយាមអោយអ្នកគិតពីខ្លួនឯង " អ្នកសមតែទទួលនូវសេចក្តីសុខសាន្តខាងផ្លូវចិត្ត និង សេចក្តីស្កប់ស្កល់ពេលនេះ ។ " ប្រសិនបើអ្នកបដិសេធន៏ផ្លូវរបស់ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការរបស់អ្នក គឺអ្នកកំពុងតែនិយាយថា អ្នកស្រលាញ់ខ្លួនឯងច្រើនជាងស្រលាញ់ព្រះជាម្ចាស់ ។ " ព្រះជាម្ចាស់មានព្រះបន្ទូលនៅក្នុង យ៉ូហាន ១៤:១៥ ថា ប្រសិនបើអ្នករាល់គ្នាស្រលាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ ។ " ប្រសិនបើធ្វើតាមការល្បួង អ្នកកំពុងតែដាក់នូវតំរូវការ និង ចំណង់របស់អ្នករំលងវិន័យរបស់ព្រះជាម្ចាស់ហើយ ។

## ៤. សាតាំងបោកបញ្ឆោតអ្នក

សាតាំងគឺជាសិល្បករជំនាញមួយរូបក្នុងការនិយាយកុហក ។ ភាគច្រើននៃការល្បួងរបស់វាមានការបោកប្រាស់ខ្លះៗនៅក្នុងនោះ ។ វាបានបោកបញ្ឆោតអោយអេវ៉ាជឿថា ប្រសិនបើនាងបានញ៉ាំផ្លែឈើនៅដើមមួយនោះ នាងនឹងមិនស្លាប់ទេ ប៉ុន្តែនឹងបានទៅជាដូចព្រះជាម្ចាស់ ។ វាពិតណាស់នាងមិនស្លាប់ទេខាងរូបកាយពេលនាងបានញ៉ាំផ្លែឈើនោះ ប៉ុន្តែ នាងមិនបានដឹងថា នាងបានស្លាប់ខាងព្រលឹងវិញ្ញាណនៅពេលនាងមិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ ។

**ក្នុងការប្រឆាំងការល្បួងនៅក្នុងអំណាចខ្លួនយើងផ្ទាល់គឺមិនអាចទៅរួចទេ ។ យើងត្រូវតែចូលទៅជិតព្រះជាម្ចាស់ ។**

មនុស្សជាច្រើនជាប់អន្ទាក់ការបោកបញ្ឆោតរបស់អារក្សសាតាំងអស់រយៈពេលយ៉ាងយូរ ។ នៅក្នុងករណីខ្លះ ស្ទើរតែគ្រប់គ្នាដឹងថាការទទួលយកជាការពិតគឺជាអ្វីដែលព្រះគម្ពីរបានប្រាប់ថាជាការបោកប្រាស់ ។ គ្រីស្តបរិស័ទថ្មីប្រហែលជាមានការពិបាកក្នុងការទទួលយកនូវអ្វីដែលព្រះគម្ពីរថែងថាជាសេចក្តីពិតនោះ នៅពេលដែលការនោះវាប្រឆាំងទៅនឹងអ្វីដែលគាត់ខ្លួនឯងមានពិសោធន៏ ។ ការណែនាំត្រូវបានផ្តល់ជូនដល់អ្នកក្នុងនាមជាគ្រូគ្រីស្តបរិស័ទពីរបៀបជួយមនុស្សម្នាក់ដែលបានជាប់អន្ទាក់របស់សាតាំង ។

២ ធីម៉ូថេ ២:២៥-២៦ ត្រូវមានចិត្តស្លូតបូត ប្រដៅពួកអ្នក ក្រែងលោព្រះអង្គនឹងប្រោសប្រទានអោយគេកែប្រែចិត្តគំនិត ដើម្បីឱ្យបានស្គាល់សេចក្តីពិតយ៉ាងច្បាស់ព្រមទាំងភ្ញាក់ស្មារតីឡើងវិញ ហើយដោះខ្លួនរួចពីអន្ទាក់របស់មារដែលបានចាប់ចងគេ បង្ខំឱ្យធ្វើតាមបំណងរបស់វា ។

អ្នកមានសេចក្តីសន្យាមកពីព្រះជាម្ចាស់ថាព្រះវិញ្ញាណបរិសុទ្ធនឹងណែនាំអោយស្គាល់សេចក្តីពិត ( យ៉ូហាន ១៦:១៣) ។ ផ្លូវតែមួយគត់ដើម្បីឱ្យអ្នកចេញពីការបញ្ឆោតរបស់សាតាំងគឺយល់ដឹងពីសេចក្តីពិត ។ ការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង ការស្តាប់ព្រះជាម្ចាស់គឺជាវិធីសាស្រ្តដ៏ល្អប្រសើរពីរយ៉ាងសំរាប់ធ្វើកិច្ចការនេះ ។ ប្រសិនបើគំនិត

ចូលមកក្នុងចិត្តគំនិតរបស់អ្នក និង អ្នកមិនច្បាស់លាស់ ប្រសិនបើគំនិតនេះមកពីព្រះអង្គ នោះ ត្រូវពិនិត្យមើលនូវអ្វីដែលព្រះគម្ពីរបានចែងអំពីកិច្ចការនេះ ។ ប្រសិនបើស៊ីគ្នាជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្នកអាចប្រាកដក្នុងចិត្តថា វាមិនអីទេសំរាប់ឱ្យអ្នកធ្វើកិច្ចការនោះ ។

### ៥. អ្នកមិនគិតអំពីសាតាំង និងការល្បួងរបស់វាអោយបានម៉ឺងម៉ាត់

ព្រះជាម្ចាស់ប្រាប់យើងនៅក្នុង យ៉ាកុប ៤:៧ អោយប្រឆាំងនឹងអារក្សសាតាំងនៅពេលដែលវាមកល្បួងអ្នក ។ មនុស្សខ្លះចង់មានសេចក្តីសុខសាន្តជាមួយព្រះជាម្ចាស់ និង ជាមួយសាតាំង ។ ពួកគេអត់អោនឱ្យសាតាំង " វាពិតជាបានធ្វើកំហុសមួយចំនួនខ្លះមែននៅក្នុងជីវិតប៉ុន្តែមិនអាក្រក់ទាំងអស់នោះទេ ។ "

យើងត្រូវតែឈរអោយបានច្បាស់លាស់នៅខាងព្រះជាម្ចាស់ និង បដិសេធនឹ៍ស្តាប់ខាងអារក្សសាតាំងនៅពេលដែលវាមក ។ ប្រសិនបើអ្នកមិនប្រឆាំងការលើកឡើងរបស់អារក្សសាតាំងទេ មិនយូរប៉ុន្មានទេ អ្នកនឹងជាប់អន្ទាក់របស់វាហើយ ។

### ៦. អ្នកប្រហែលជាយល់ថាវាមិនអីទេ ក្នុងការធ្វើអំពើបាប ព្រោះព្រះជាម្ចាស់តែងតែអត់ទោសជានិច្ច

មនុស្សដែលគិតថាគាត់អាចធ្វើអំពើបាបថ្ងៃនេះ និង ទទួលការអត់ទោសពីព្រះជាម្ចាស់យ៉ាងងាយស្រួលពេលដែលគាត់ចង់នោះ គាត់កំពុងតែយកករបស់គាត់លអន្ទាក់ហើយ ។ អាកប្បកិរិយាប្រភេទនេះផ្ទុយពីអ្វីដែលព្រះគម្ពីរបង្រៀន ពីផ្លូវត្រឹមត្រូវដើម្បីរស់នៅនោះ ។ ( សូមមើល សុភាសិត ជំពូក ទី ១ ជាពិសេស ខ ទី ២០-៣៣) ។ យើងមិនអាចរំលោភបំពានសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់នោះទេ ។ ការសារភាពពិតប្រាកដមានន័យថា បែរចេញពីអំពើបាប និង ចាប់ផ្តើមផ្លូវថ្មីក្នុងការឆ្លើយតបចំពោះតំរូវការ ឬក៏ការល្បួងពិសេសណាមួយនោះ ។

### ៧. អ្នកមិនអាចឃ្មុំគ្រងចំណង់របស់អ្នកបាន

ចំណង់ និង ការស្រលាញ់ងប់ងល់របស់អ្នកអាចមានកំឡាំងខ្លាំងក្លាណាស់ប្រសិនបើអ្នកបណ្តោយទៅតាមវានោះ ។ តាមពិតទៅ វានឹងគ្រប់គ្រងគំនិត និង សកម្មភាពរបស់អ្នកប្រសិនបើអ្នកមិនបញ្ឈប់វានោះទេ ។ អារម្មណ៍របស់អ្នកទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងចំណង់របស់អ្នក ។ អ្នកប្រហែលជាបានឃើញមនុស្សដែលខឹងខ្លាំង ហើយគាត់បាត់បង់នូវការគ្រប់គ្រងសកម្មភាពធម្មតារបស់គាត់ ។ នៅក្នុងពេលវេលាដូចនេះ មនុស្សតែងតែនិយាយ ឬក៏ធ្វើអ្វីមួយ ហើយក្រោយមកគាត់ស្តាយក្រោយវិញនូវអ្វីដែលបានធ្វើ

ប្រសិនបើអ្នកមិនប្រុងប្រយត្ន័ ចំណង់របស់អ្នកអាចក្លាយទៅជាខ្លាំងក្លា ដែលអ្នកមិនមានអំណាចបដិសេធនឹបានទេ ។ នៅក្នុង កណ្ឌ័គម្ពីរសុភាសិត ព្រះជាម្ចាស់បានប្រមានយើងអោយរក្សាអោយបាននូវការគ្រប់គ្រងចំណង់របស់យើង ។

**សុភាសិត ៧:២៤-២៥ៈ ឥឡូវនេះកូនអើយ ចូរស្តាប់ឪពុក ចូរត្រង់ត្រាប់សេចក្តីដែលឪពុកទូន្មាន ។ កុំបាក់ទឹកចិត្តទៅតាមស្ត្រីប្រភេទនេះឡើយ ... ។**

ព្រះជាម្ចាស់បានផ្តល់នូវការទូន្មាននេះដល់យើងនៅក្នុងសុភាសិត នៅពេលទ្រង់មានបន្ទូលពីរបៀបបោះបង់ចោលការល្បួងខាងផ្លូវភេទ ។

## ៨. អ្នកជាមនុស្សស្មោះត្រង់ ប៉ុន្តែនៅតែធ្វើតាមការល្បួង

ឧទាហរណ៏ថា អ្នកបានក្លាយជាគ្រីស្តបរិស័ទអស់រយៈពេលជាច្រើនខែមកហើយ ហើយអ្នកពិតជាចង់បំរើព្រះជាម្ចាស់ ។ ប៉ុន្តែ មានការល្បួងមួយ ដែលអ្នកធ្វើតាមវារហូតពេលដែលវាមក ។ អ្នកដឹងថាវាគឺជាអំពើបាប ។ អ្នកស្អប់វាណាស់ និង មានអារម្មណ៏សោកស្តាយរាល់ពេលដែលអ្នកធ្វើវា ។ ប៉ុន្តែ អ្នកមើលទៅដូចជាមិនអាចយកជ័យជំនះលើវាបានទេ ។ តើអ្វីគឺជាដំណោះស្រាយចំពោះបញ្ហានេះ ?

ទី ១អ្នកត្រូវតែមានជំនួយមកពីព្រះជាម្ចាស់ក្នុងការយកជ័យជំនះនៅលើការល្បួង ប្រសិនបើអ្នកកំពុងតែព្យាយាមរស់នៅជីវិតគ្រីស្តបរិស័ទរបស់អ្នកនៅក្នុងកំឡាំងខ្លួនអ្នកផ្ទាល់ នោះកិច្ចការទី ១ ដែលអ្នកត្រូវធ្វើគឺ អ្នកត្រូវធ្វើអោយប្រាកដថា ព្រះគ្រីស្តពិតជាអង្គតែមួយគត់គ្រប់គ្រងលើជីវិតរបស់អ្នក ។ បន្ទាប់មកអ្នកត្រូវតែដាក់ព្រះជាម្ចាស់មុនដោយមនសិការរបស់អ្នកនៅក្នុងគ្រប់ស្ថានភាពដែលអ្នកប្រឈមមុខ ។

អ្នកត្រូវតែស្មោះត្រង់ជាមួយនឹងព្រះជាម្ចាស់ ។ ខណៈពេលនៃការល្បួង អ្នកគួរតែប្រាប់ព្រះជាម្ចាស់នូវអ្វីដែលកំពុងតែកើតឡើងនៅខាងក្នុង ។ ប្រសិនបើអ្នកពិតជាមានអារម្មណ៏ចង់ធ្វើតាមការល្បួង សូមសារភាពកិច្ចការនេះទៅដល់ព្រះជាម្ចាស់ ។ វាងាយស្រួលអធិស្ឋានដល់ព្រះជាម្ចាស់បន្ទាប់ពីការល្បួងបានរំលងផុតទៅ ហើយអ្នកបានបរាជ័យចំពោះកិច្ចការនោះ ។ វាប្រហែលជាពិបាកខ្លាំងក្នុងការយកភ្នែករបស់អ្នកចេញពីការល្បួងមុននឹងអ្នកអាចធ្វើតាមការល្បួង ហើយ និយាយទៅកាន់ព្រះជាម្ចាស់មុននឹងចំណង់ ឬក៏តំរូវការរបស់អ្នកបានបំពេញនោះ ។ ប៉ុន្តែ វាគឺជាផ្លូវដ៏មានអំណាចបំផុតក្នុងការពារកុំឱ្យអ្នកធ្លាក់ ។

ផ្នែកដទៃទៀតនៃបញ្ហារបស់អ្នកគឺប្រហែលជាអ្នកមិនបានធ្វើកិច្ចការបំពេញតំរូវការ ឬក៏ ចំណង់របស់អ្នកតាមផ្លូវរបស់ព្រះជាម្ចាស់នោះទេ ។ អ្នកប្រហែលជាដឹងថា ការ

ធ្វើតាមការល្បួងរបស់អារក្សសាតាំងគឺជាអំពើបាប ប៉ុន្តែនៅពេលជាមួយគ្នានោះ មិនបាន ធ្វើកិច្ចការដើម្បីស្វែងរកអោយឃើញនូវដំណោះស្រាយរបស់ព្រះជាម្ចាស់ចំពោះបញ្ហានោះ ទេ ។ ឬក៏ ប្រហែលជាអ្នកស្គាល់ផ្លូវរបស់ព្រះជាម្ចាស់ក្នុងការបំពេញតួនាទីរបស់អ្នក ប៉ុន្តែ មិនបានប្តេជ្ញាចិត្តធ្វើតាមព្រះជាម្ចាស់ ។ អ្នកត្រូវតែធ្វើការសំរេចចិត្តដើម្បីធ្វើតាមផ្លូវរបស់ ព្រះជាម្ចាស់ ហើយមិនត្រូវអនុញ្ញាតិឱ្យកិច្ចការអ្វីមួយផ្លាស់ប្តូរចិត្តគំនិតរបស់អ្នកនោះទេ។

## គ. តើអ្នកគួរតែធ្វើអ្វី បន្ទាប់ពីអ្នកបានធ្វើតាមការល្បួង?

ប្រសិនបើអ្នកបានធ្វើតាមការល្បួង និង ធ្វើអំពើបាប ព្រះជាម្ចាស់មិនបដិសេធន៏អ្នកនោះ ទេ ។ កុំនៅតែបន្តធ្វើបាបតទៅទៀត ។ ទោះបីជាបរាជ័យនោះវាធំ ឬក៏ តូចក៏ដោយ អ្នកចាំបាច់ត្រូវតែចាត់វិធានការជាមួយនឹងវាភ្លាមៗ ។

### ១. សារភាពបរាជ័យរបស់អ្នក

កុំសាកល្បងប្រងើយកន្តើយអំពើបាបរបស់អ្នក ឬក៏ បិទបាំងវាអោយសោះ ។ សារភាពអំពើបាបនោះទៅព្រះជាម្ចាស់ និង ខ្លួនអ្នកផ្ទាល់ ។ ព្រះជាម្ចាស់នឹងអត់ទោស ឱ្យអ្នក កាលណាអ្នកសារភាពអំពើបាបរបស់អ្នក ។ ការសារភាពអំពើបាបរបស់អ្នកអាច ជាជំហានទី ១ ដើម្បីយកជ័យជំនះលើបញ្ហាដែលបាននាំឱ្យអ្នកបរាជ័យ ។ វានឹងមាន ប្រយោជន៏ផងដែរសំរាប់អ្នកក្នុងការសារភាពអំពើបាបរបស់អ្នក ដល់គ្រីស្តបរិស័ទដទៃ ទៀតប្រសិនបើអ្នកយល់ថា មនុស្សនោះអាចជួយអ្នកអោយរក ឃើញផ្លូវរបស់ព្រះជា ម្ចាស់ក្នុងការយកជ័យជំនះលើបញ្ហានេះ ។

ប្រសិនបើអំពើបាបរបស់អ្នកប៉ះពាល់ដល់ដទៃទៀត អ្នកត្រូវតែទៅសារភាព អំពើបាបរបស់អ្នកចំពោះពួកគេ និង សូមការអត់ទោសពីពួកគេ ។

### ២. កត់សំគាល់តួនាទីការនិងចំណង់នៅក្នុងជីវិតរបស់អ្នក និង ធ្វើផែនការដើម្បីបំពេញកិច្ចការនេះទៅតាមផ្លូវរបស់ព្រះអង្គ

បំពេញតួនាទីការ និង ចំណង់របស់អ្នក ទៅតាម ផ្លូវរបស់ព្រះជាម្ចាស់ ។

អ្នកត្រូវតែស្គាល់ផ្លូវរបស់ព្រះជាម្ចាស់ក្នុងការបំពេញតួនាទីការ និង ចំណង់របស់អ្នក ប្រសិនបើអ្នកចង់មានជ័យជំនះប្រឆាំងការល្បួងដែលនាំអោយធ្វើអំពើបាបនោះ ។ ទោះបីជាអ្នកប្រហែលជានៅតែមានពិសោធន៏ការស្កប់ស្កល់ចិត្តជាបណ្តោះអាសន្នក្នុងការ បំពេញតួនាទីការតាមផ្លូវសាតាំងក៏ដោយ ក៏អ្នកដឹងច្បាស់លាស់ថា ដំណោះស្រាយរបស់វា គ្រាន់តែជាបណ្តោះអាសន្នតែប៉ុណ្ណោះ ។ តួនាទីការរបស់អ្នកនឹងត្រឡប់មកវិញ ដូច្នេះរៀប

ចំផែនការថ្ងៃនេះពីរបៀបដែលអ្នកនឹងបំពេញវានៅពេលក្រោយទៀត ។ អ្នកប្រហែលជាចង់សួរគ្រីស្តបរិស័ទដទៃទៀតអោយជួយអ្នក ឬក៏ អធិស្ឋានជាមួយអ្នក ។

### ៣. ទាយតំលៃការតាំងចិត្តរបស់អ្នកចំពោះព្រះគ្រីស្ទ

នៅពេលដែលអ្នកបរាជ័យ ឬក៏ ធ្វើតាមការល្បួងរបស់អារក្សសាតាំង អ្នកអាចប្រើកិច្ចការនេះជាឱកាសដើម្បីចូលទៅជិតព្រះជាម្ចាស់ ។ ប្រាប់ព្រះជាម្ចាស់នូវអ្វីដែលអ្នកចង់ធ្វើ ហើយបន្ទាប់មកធ្វើការផ្លាស់ប្តូរអ្វីដែលចាំបាច់ត្រូវផ្លូវដើម្បីអោយព្រះគ្រីស្តជាព្រះទី ១ នៅក្នុងជីវិតរបស់អ្នក ។

### ៤. ប្រកាសសេចក្តីសន្យារបស់ព្រះជាម្ចាស់ដើម្បីទទួលអំណាច

សេចក្តីសន្យារបស់ព្រះជាម្ចាស់មិនគ្រាន់តែសំរាប់អ្នកដឹកនាំគ្រីស្តបរិស័ទល្បីឈ្មោះនៅក្នុងពិភពលោកនេះទេ ។ អ្នកមានសិទ្ធិដូចគ្នាប្រកាសនូវសេចក្តីសន្យាទាំងនេះដូចអ្នកដឹកនាំល្បីៗទាំងនោះដែរ ។ សេចក្តីសន្យានៅក្នុង ភីលីព ៤:១៣ គឺជាសេចក្តីពិតសំរាប់អ្នក " ខ្ញុំអាចទ្រាំបានទាំងអស់ដោយរួមជាមួយព្រះអង្គដែលប្រទានកំឡាំងអោយខ្ញុំ ។ " សេចក្តីសន្យានៅក្នុង ១ កូរិនថូស ១០:១៣ គឺជាសេចក្តីសន្យាមួយដ៏ល្អដើម្បីចងចាំ និង លើកឡើងចំពោះខ្លួនឯង ជាពិសេសនៅពេលដែលអ្នកមិនមានអារម្មណ៍ជិតស្និទ្ធជាមួយព្រះជាម្ចាស់ ។ សូមរក ២ គម្ពីរដទៃទៀតដែលទាក់ទងទៅនឹងការល្បួងជាក់លាក់ណាមួយដែលពិបាកបំផុតសំរាប់អ្នកយកជ័យជំនះ និង និយាយ២ គម្ពីរទាំងនោះដាក់ដល់ខ្លួនអ្នកឱ្យបានជារៀងរាល់ថ្ងៃ ។

### ៥. កុំបន្តដំណើរនៃភាពមានកំហុសតទៅទៀត

កុំរស់នៅក្នុងបរាជ័យរបស់អ្នក ។ អារក្សសាតាំងវាចូលចិត្តចោទប្រកាន់អ្នកបន្ទាប់ពីអ្នកទទួលបរាជ័យ ។ វានឹងធ្វើគ្រប់អ្វីៗទាំងអស់ដែលវាអាចធ្វើទៅបានបង្ខូចទឹកចិត្តអ្នក និង ធ្វើឱ្យអ្នកជឿថា អ្នកជាមនុស្សបរាជ័យទាំងស្រុង ។ កុំឱ្យវាបោកបញ្ឆោតអ្នកជាមួយនឹងកិច្ចការទាំងនេះ ។ ប្រសិនបើអ្នកបានសារភាពអំពើបាបរបស់អ្នកដល់ព្រះអង្គហើយ អ្នកមិនចាំបាច់ចំណាយពេលវេលារស់នៅក្នុងភាពសោកសៅ និង ការដាក់ទោសខ្លួនឯងសំរាប់ការបរាជ័យរបស់អ្នកនោះទេ ។

សាតាំងវាចង់អោយអ្នកមានអារម្មណ៍សោកស្តាយសំរាប់ខ្លួនឯងផ្ទាល់ និង ស្លុតចិត្តចំពោះបរាជ័យរបស់អ្នក ដែលធ្វើអោយអ្នកលែងចង់រស់នៅជាជីវិតគ្រីស្តបរិស័ទទៀត ។ ជាច្រើនដង វានឹងលើកឡើងពីការបរាជ័យរបស់អ្នកក្នុងរយៈពេល ពីរបីថ្ងៃ, រយៈពេលជាច្រើនសប្តាហ៍ ឬក៏ មួយឆ្នាំក្រោយមកវាលើកពីការបរាជ័យនេះ ។ ពេលនោះវានឹងចោទ

ប្រកាន់អ្នក " មើលអ្វីដែលអ្នកបានធ្វើ! តើវាមិនអាក្រក់ទេឬ? អ្នកបានធ្វើអំពើបាបយ៉ាងពិតប្រាកដមែន! គំរូជាគ្រីស្ទបរិស័ទរបស់អ្នកពិតជាអាក្រក់ណាស់ អ្នកគួរតែមានទូវអារម្មណ៍ថាមានកំហុសសំរាប់អ្វីដែលអ្នកបានធ្វើ ។ " កុំស្តាប់ការកុហករបស់វា ។ ប្រសិនបើព្រះជាម្ចាស់បានអត់ទោសនោះអ្នកមិនចាំបាច់លើកវាឡើងម្តងហើយម្តងទៀតនោះទេ។

## សេចក្តីសន្និដ្ឋាន

ពិតណាស់ អ្នកនឹងបរាជ័យយូរៗម្តង ដូចជាគ្រីស្ទបរិស័ទដទៃទៀតដែរ ។ ប៉ុន្តែសូមចងចាំ ត្រូវអំពាវនាវដល់ព្រះអង្គដើម្បីអោយទ្រង់ផ្តល់កំឡាំង និង ប្រាជ្ញាដើម្បីប្រឆាំងរាល់ការល្បួងរបស់អារក្សសាតាំងដែលបញ្ជូនមក ។ ប្រសិនបើអ្នកបង្កើតគំរូនៃការឆ្លើយតបតាមបែបព្រះគម្ពីរ អ្នកនឹងមើលឃើញថា អារក្សសាតាំងវានឹងភៀសខ្លួនចេញពីអ្នកជាពុំខាន ។ ព្រះជាម្ចាស់បានសន្យាកិច្ចការនេះនឹងកើតឡើង-សូមមើលយ៉ាកុប៤:៧ ។ អ្នកត្រូវតែប្រុងប្រៀបខ្លួនសំរាប់ការល្បួង និង ធ្វើតាមគំរូរបស់ព្រះគ្រីស្ទក្នុងការចូលទៅជិតព្រះអង្គរាល់ពេលដែលអ្នកប្រឈមមុខនឹងការល្បួង ។ ការបំពេញតំរូវការ និង ចំណង់របស់អ្នកតាមផ្លូវរបស់ព្រះជាម្ចាស់នឹងជួយអ្នកឱ្យពិសោធន៍នូវជីវិតដ៏ប្រសើរបំផុតនៅលើផែនដីនេះ ការស្តាប់ស្តល់នឹងមានរហូត និង ពេញដោយ សេចក្តីសុខសាន្ត ។